# មេរៀនទី ៦ ក្រុមជំនុំ៖ សហគមន៍នៃប្រជារាស្ត្រ របស់ព្រះជាម្ចាស់

តើអ្នកដែលមើលទៅកាន់ក្មេងលេងជាមួយគ្នា ហើយសំគាល់ឃើញពីភាពធម្មតាដែលពួកគេនៅជាមួយគ្នានោះដែរឬទេ? ការនេះបង្ហាញថា មនុស្សគឺជាភាវៈនៃសង្គម ហើយតាមធម្មជាតិរបស់យើង យើងត្រូវបង្កើតទំនាក់ទំនង និង មានការប្រកបរួបរួមជាមួយនឹងមនុស្សដទៃទៀតដែលដូចនឹងយើង។ ដូច្នេះហើយមិនចាំបាច់ឆ្ងល់ទេថា តើហេតុអ្វីបានជាព្រះយេស៊ូបង្កើតសហគមន៍នៃមនុស្សដែលមានគំនិតដូចគ្នា ដែលជាក្រុមជំនុំរបស់ទ្រង់នោះ នោះក៏ដើម្បីឲ្យតាមរយៈសហគមន៍នេះ បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់អាចនឹងបានសម្រេច។ ក្រុមជំនុំ គឺជាសហគម៍នៃមនុស្សរបស់ព្រះជាម្ចាស់ដែលមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក ដោយផ្អែកលើទំនាក់ទំនង់ផ្ទាល់ខ្លួនរបស់ពួកគេជាមួយនឹងព្រះយេស៊ូគ្រិស្ត។

លោកពេត្រុសបានប្រកាសថា៖ "ពីដើមអ្នករាល់គ្នាមិនមែនជាសាសន៍ណាមួយទេ តែឥឡូវនេះជាសាសន៍របស់ព្រះវិញ" (គម្ពីរ១ពេត្រុស ២:១០គប)។ ពីមុនយើងស្ថិតនៅខាងក្រៅ អំពើបាបរបស់យើងបានរារាំងយើងពីព្រះជាម្ចាស់។ ទោះជាយ៉ាងណា នៅពេលដែលយើងបានទទួលស្គាល់ព្រះគ្រិស្ត។ ទំនាក់ទំនងថ្មីមួយនេះ ក៏បាននាំយើងចូលទៅក្នុងទំនាក់ទំនងថ្មីជាមួយនឹងអ្នកជឿដទៃទៀត។ យើងបានក្លាយជាទិដ្ឋភាពមួយនៃគ្រួសាររបស់ព្រះជាម្ចាស់ គឺក្រុមជំនុំរបស់ទ្រង់នោះឯង។

នៅក្នុងមេរៀននេះ យើងនឹងសិក្សាឧបករណ៍ដែលព្រះជាម្ចាស់បានជ្រើសរើស ដើម្បីថ្វាយសិរីរុងរឿងទៅដល់ទ្រង់ ដើម្បីបីបាច់រក្សាជីវិតខាងឯវិញ្ញាណ និង ដើម្បីចែកចាយដំណឹងល្អនេះទៅកាន់មនុស្សដទៃទៀត។ នៅពេលដែលយើងកំពុងសិក្សាអំពីក្រុមជំនុំ និង ស្វែងយល់អំពីអត្ថន័យដ៏ពិតរបស់ក្រុមជំនុំ យើងនឹងអាចឃើញពីតម្លៃដែលព្រះអម្ចាស់បានដាក់ឲ្យក្រុមជំនុំ ដែលនាំឲ្យទ្រង់ឈានទៅដល់ការលះបង់ព្រះជន្មរបស់ទ្រង់ដើម្បីក្រុមជំនុំនោះ (គម្ពីរអេភេសូ ៥:២៥)។

## គម្រោងមេរៀន

ក. អ្វីដែលជាក្រុមជំនុំ

ខ. ពេលដែលក្រុមជំនុំចាប់ផ្ដើម

គ. លក្ខណៈរបស់ក្រុមជំនុំ

ឃ. អ្វីដែលក្រុមជំនុំធ្វើ

## ទិស្ដុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹងៈ

១. ប្រាប់និយមន័យនៃពាក្យក្រុមជំនុំ និង បែងចែករវាងនិយមដែលមាននៅក្នុងព្រះគម្ពីរ និង និយមន័យដែលនៅក្រៅពីព្រះគម្ពីរ។

២. ប្រាប់អំពីព្រឹត្តិការណ៍នៅក្នុងព្រះគម្ពីរចំនួនពីរយ៉ាង ដែលបង្ហាញពីពេលដែលក្រុមជំនុំចាប់ផ្ដើមកើតមានឡើង និង ធ្វើការរៀបរាប់អំពីសកម្មភាពទាំងប្រាំពីរយ៉ាងរបស់អ្នកជឿកាលពីជំនាន់មុន

៣. ស្គាល់លក្ខណៈដែលរៀបរាប់ពីនិស្ស័យរបស់ក្រុមជំនុំ។

៤. ពិភាក្សាអំពីការចូលរួមថ្វាយបង្គំ និង បកស្រាយពីអ្វីដែលយើងថ្វាយទៅកាន់ព្រះជាម្ចាស់ក្នុងពេលថ្វាយបង្គំទ្រង់។

៥. បកស្រាយពីអត្ថន័យនៃពាក្យ *កសាងឡើង* និង ទំនាក់ទំនងរវាងព្រះអំណោយទាន និង ផលផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធ និង ក្រុមជំនុំ។

៦. បកស្រាយពីរបៀបដែលសេចក្ដីបង្រៀនរបស់ព្រះយេស៊ូ ទាក់ទងនឹងបេសកកម្មរបស់ក្រុមជំនុំ គួរតែត្រូវបានយកទៅដាក់ឲ្យប្រតិបត្តិ(អនុវត្ត)។

## សកម្មភាពក្នុងការសិក្សា

១. ដើម្បីជាបង្អែកសម្រាប់មេរៀននេះ សូមអានគម្ពីរកិច្ចការជំពូក២ គម្ពីរ១កូរិនថូស ១២:១២-៣១ គម្ពីររ៉ូមជំពូក១២ គម្ពីរអេភេសូ ៤:១-១៦; ៥:២២-៣៣។

២. សិក្សាតាមលំដាប់លំដោយមេរៀន ដោយផ្អែកទៅតាមក្បួនដែលបានប្រាប់នៅក្នុងមេរៀនទី១។ បើកមើលនិយមន័យពាក្យសំខាន់ទាំងឡាយណាដែលថ្មីសម្រាប់អ្នក។

## ពាក្យសំខាន់

| | | |
|---|---|---|
| រនាំង | ការកសាងឡើង | ទំនាក់ទំនង |
| ការបំផុស | តួនាទី | សង្គម |
| សហគមន៍ | បញ្ញាត្តិ | ជាសាកល |
| ភាពរស់រវើក | | |

# ក. អ្វីដែលជាក្រុមជំនុំ

**វត្ថុបំណងទី១.** *ប្រាប់និយមន័យនៃពាក្យក្រុមជំនុំ និង បែងចែករវាងនិយមន័យដែលមាននៅក្នុងព្រះគម្ពីរ និង និយមន័យដែលនៅក្រៅពីព្រះគម្ពីរ។*

## *លំហាត់អនុវត្តន៍*

១ ឧបមាថា អ្នកបានលើកយកពាក្យ*ក្រុមជំនុំ* ទៅនិយាយជាមួយអ្នកដែលមិនធ្លាប់បានឮពាក្យនេះពីមុនមក ហើយគាត់សួរទៅកាន់អ្នកថា៖ "តើ*ក្រុមជំនុំ* មានន័យយ៉ាងដូចម្តេច?" ដោយយោងទៅតាមបទពិសោធន៍របស់អ្នក ចូរសរសេរចម្លើយខ្លីមួយសម្រាប់សំណួរនេះនៅក្នុងសៀវភៅកត់ត្រារបស់អ្នក។

ប្រសិនបើអ្នកដូចជាមនុស្សភាគច្រើន ក្នុងពេលសព្វថ្ងៃនេះ អ្នកប្រហែលជាឆ្លើយទៅកាន់សំណួរខាងលើនេះថា៖ "ក្រុមជំនុំគឺជាកន្លែងសម្រាប់ឲ្យមនុស្សមកជួបជុំគ្នាដើម្បីធ្វើការថ្វាយបង្គំ។" ប្រសិនបើអ្នកចង់ឲ្យកាន់តែច្បាស់លាស់ជាងនេះទៀត អ្នកប្រហែលជានឹងឆ្លើយថា៖ "ពាក្យថា *ក្រុមជំនុំ* សំដៅទៅលើស្ថាប័នមួយដែលបង្កើតឡើងពីមនុស្សមួយក្រុមដែលនៅកន្លែងផ្សេងៗពីគ្នា ដែលប្រកាន់យកទស្សនវិស័យគោលលទ្ធិដូចគ្នា ត្រូវបានដឹកនាំដោយក្រឹត្យវិន័យដូចគ្នា និង មានគោលដៅស្រដៀងគ្នា។

ចម្លើយទាំង ពីរនេះផ្តល់ឲ្យយើងនូវគំនិតខ្លះៗ អំពីរបៀបដែលពាក្យថា *ក្រុមជំនុំ* នេះ ត្រូវបានមនុស្សជាច្រើនឲ្យនិយមន័យ ហើយចម្លើយទាំងពីរនេះ ក៏អាចចាត់ទុកថាត្រឹមត្រូវ បើគិតតាមការយល់ដឹងសម័យថ្មីទៅលើ ពាក្យនេះ។ ទោះជាយ៉ាងណា នៅពេលដែលព្រះគម្ពីរថ្លែងពីក្រុមជំនុំ នោះពាក្យនេះន័យជាក់លាក់ជាងអ្វីដែលយើងបានឃើញនៅក្នុងចម្លើយទាំងនេះទៅទៀត។

តាមការពិត ព្រះគម្ពីរមិនមែនសំដៅទៅលើ*អគារ* ណាមួយថាជាក្រុមជំនុំដូចដែលយល់ឃើញសព្វថ្ងៃនេះទេ ប៉ុន្តែសំដៅទៅលើ*មនុស្ស* ដែលប្រកបរួបរួមនៅក្នុងក្រុមជំនុំនោះវិញ។ ព្រះគម្ពីរក៏មិនបានថ្លែងអំពីក្រុមជំនុំថាជា *ស្ថាប័ន* ណាមួយផងដែរ។ សព្វថ្ងៃ មនុស្សដែលសំគាល់ពាក្យ*ក្រុមជំនុំ* ទៅតាមរបៀបនេះគឺចងភ្ជាប់ពាក្យនេះទៅជាមួយនឹង និកាយ ដូចជាកាតូលិក បាទីស្ត មេតូឌីស ឬ និកាយដទៃផ្សេងទៀត។

នៅក្នុងអត្ថន័យរបស់ព្រះគម្ពីរ មាននិយមន័យចំនួនពីរយ៉ាងសម្រាប់ពាក្យថា *ក្រុមជំនុំ* នេះ។ ពាក្យឫសគល់ដែលបានបង្កើតបានជាពាក្យក្រិកថា *អ៊ីក្លេស៊ា (ekklesia)* ដែលប្រែមកថា "ក្រុមជំនុំ" នៅក្នុងគម្ពីរសម្ពន្ធមេត្រីថ្មី បានផ្តល់ឲ្យយើងនូវរូបភាពរបស់មនុស្សដែលបានឆ្លើយតបនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់ ។ ដោយបានឆ្លើយតបទៅនឹងការត្រាស់របស់ទ្រង់ ហើយបានទទួលស្គាល់ថាព្រះយេស៊ូគឺជាព្រះអម្ចាស់ ពួកគេបានក្លាយជាសមាជិកគ្រួសាររបស់ទ្រង់ ។ ពួកគេប្តេជ្ញាចិត្ត ចំពោះកិច្ចការចែកចាយដំណឹងល្អ ដូចដែលព្រះអម្ចាស់របស់ពួកគេបានណែនាំទៅកាន់ពួកគេ។ ពួកគេគឺជាសហគមន៍ នៃអ្នកស្តាប់បង្គាប់ ដែលបានប្រមូលផ្តុំគ្នាដើម្បីធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់។ បើមើលទៅលើរូបភាពធំមួយ សហគមន៍នៃអ្នកជឿដែលបានទទួលស្គាល់ថាព្រះយេស៊ូគឺជាព្រះអម្ចាស់ ជាតំណាងឲ្យ *ក្រុមជំនុំទូ*

*ទាំងសាកល* តែម្ដង នោះក៏ត្រូវបានគេហៅថា *ក្រុមជំនុំឥតរូប* នោះឯង។ ពាក្យនេះ គឺបូករួមបញ្ចូលអ្នកជឿទាំងអស់ នៅគ្រប់ទីកន្លែងដែលមានជំនឿដូចគ្នាទៅលើព្រះយេស៊ូ និង មានភាពស្មោះស្ម័គ្រជាមួយទ្រង់។

បើមើលមកលើរូបភាពតូចវិញ *ក្រុមជំនុំ* គឺសំដៅទៅលើការប្រមូលផ្ដុំគ្នា ឬ ការជំនុំមនុស្ស។ អ្នកទាំងនេះគឺសុទ្ធតែជាអ្នកជឿដែលមកពីកន្លែងណាមួយ ដែលមានជំនឿ និង ភាពស្មោះស្ម័គ្រដូចគ្នាទៅចំពោះព្រះយេស៊ូគ្រិស្ដ និង ជាអ្នកដែលជួបជុំគ្នាដើម្បីធ្វើការថ្វាយបង្គំរួមគ្នា។ ពួកអ្នកទាំងនោះ គឺគេហៅថា *ក្រុមជំនុំតាមតំបន់* ឬ *ក្រុមជំនុំមានរូប។* ឧទាហរណ៍ជាក់ស្ដែងអំពីក្រុមជំនុំតាមតំបន់ទាំងនេះ គឺឃើញមាននៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មីៈ

សូមជំរាបមកបងប្អូនទាំងអស់នៅក្រុងរ៉ូម ជាអ្នកដែលព្រះជាម្ចាស់ស្រឡាញ់ និងត្រាស់ហៅអោយធ្វើជាប្រជាជនដ៏វិសុទ្ធ។ (គម្ពីររ៉ូម ១:៧)

សូមជំរាបមកក្រុមជំនុំ*របស់ព្រះជាម្ចាស់នៅក្រុងកូរិនថូស។ ព្រះជាម្ចាស់បានត្រាស់ហៅបងប្អូនអោយធ្វើជាប្រជារាស្ដ្រដ៏វិសុទ្ធ (គម្ពីរ១កូរិនថូស ១:២)

សូមជំរាបមកក្រុមជំនុំទាំងឡាយនៅស្រុកកាឡាទី។ (គម្ពីរកាឡាទី ១:២)

សូមជំរាបមកប្រជាជនដ៏វិសុទ្ធ*ទាំងអស់ ដែលរួមជាមួយព្រះគ្រិស្ដយេស៊ូនៅក្រុងភីលីព ព្រមទាំងអស់លោកអភិបាល និងអ្នកជំនួយសូមជ្រាប។ (គម្ពីរភីលីព ១:១)

អ្វីដែលសំខាន់នោះ យើងអាចនិយាយបានថា ក្រុមជំនុំដែលត្រូវបានលើកឡើងនៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី គឺជាសហគមន៍នៃមនុស្សរបស់ព្រះជាម្ចាស់។ ពាក្យថា *សហគមន៍* គឺមានសារៈសំខាន់ណាស់ក្នុងការរៀបរាប់អំពីក្រុមជំនុំ ព្រោះពាក្យនេះនិយាយអំពីបុគ្គលអ្នកជឿ ដែលរួមគ្នាក្រោមគោលបំណង ធ្វើការប្រកបគ្នា និង ចែកចាយជាមួយគ្នា នៅពេលដែលពួកគេថ្វាយបង្គំព្រះជាម្ចាស់ជាមួយគ្នា។ សហគមន៍ខាងឯវិញ្ញាណនេះ គឺត្រូវរៀបរាប់នៅក្នុងគម្ពីរ កិច្ចការ ២:៤២-៤៧។

សិស្សទាំងនោះព្យាយាមស្ដាប់សេចក្ដីបង្រៀនរបស់ក្រុមសាវ័ក* រួមរស់ជាមួយគ្នាជាបងប្អូន ធ្វើពិធីកាច់នំបុ័ង* និងព្យាយាមអធិស្ឋាន។ មនុស្សម្នាកោតស្ញប់ស្ញែងគ្រប់ៗគ្នា ដ្បិតក្រុមសាវ័កបានសំដែងឫទ្ធិបាដិហារិយ៍ និងធ្វើទីសំគាល់ផ្សេងៗជាច្រើន។ អស់អ្នកដែលបានជឿលើព្រះអម្ចាស់មានចិត្តគំនិតតែមួយ ហើយយករបស់របរដែលខ្លួនមាន មកដាក់រួមគ្នាទាំងអស់។ គេលក់ទ្រព្យសម្បត្តិ និងអ្វីៗជារបស់ខ្លួនយកប្រាក់មកចែកគ្នាតាមសេចក្ដីត្រូវការរបស់ពួកគេម្នាក់ៗ។ ជារៀងរាល់ថ្ងៃ គេរួមចិត្តគំនិតគ្នាព្យាយាមចូលព្រះវិហារ* ធ្វើពិធីកាច់នំបុ័ងនៅតាមផ្ទះ ព្រមទាំងបរិភោគអាហារជាមួយគ្នាយ៉ាងសប្បាយរីករាយ និងដោយចិត្តស្មោះសរផង។ គេនាំគ្នាសរសើរតម្កើងព្រះជាម្ចាស់ ហើយប្រជាជនទាំងមូលគោរពរាប់អានពួកគេទាំងអស់គ្នា។ ព្រះអម្ចាស់បន្ថែមចំនួនអ្នកដែលព្រះអង្គបានសង្គ្រោះ មកក្នុងក្រុមរបស់គេជារៀងរាល់ថ្ងៃ។

ព្រះគម្ពីរបង្រៀនថា ក្រុមជំនុំគឺជាឧបករណ៍ដែលព្រះជាម្ចាស់បានជ្រើសរើសដើម្បីបំពេញមុខងារទាំងនេះៈ

១. ក្រុមជំនុំ ផ្ដល់ឲ្យមានការថ្វាយបង្គំរួមគ្នា (គម្ពីរយ៉ូហាន ៤:២០-២៤ ហើយប្រៀបធៀបជាមួយគម្ពីរហេប្រឺ ១០:២៥)

២. ក្រុមជំនុំផ្ដល់នូវការលូតលាស់សម្រាប់វិញ្ញាណរបស់អ្នកជឿ (គម្ពីរអេភេសូ ៤:១៣-១៦)។

៣. ក្រុមជំនុំពង្រីកដំណឹងល្អ អំពីសេចក្តីសង្គ្រោះដែលមាននៅក្នុងព្រះគ្រិស្ត ទៅកាន់មនុស្សដទៃទៀត (គម្ពីរម៉ាថាយ ១៦:១៨; ២៤:១៤; ២៨:១៨-២០)។

យើងនឹងចូលទៅមើលលើតួនាទីនីមួយៗ ឲ្យបានកាន់តែពេញលេញនូវទិដ្ឋភាពក្រោយទៀតក្នុងមេរៀននេះ។

ជាញឹកញាប់ យើងឃើញពាក្យថា *ក្រុមជំនុំរបស់ព្រះជាម្ចាស់* ឬ *ក្រុមជំនុំរបស់ព្រះគ្រិស្ត* នៅក្នុងបទគម្ពីរ។ ពាក្យទាំងអស់នេះ ចង្អុលបង្ហាញថា លក្ខណៈសំខាន់នៃការជំនុំនេះ មិនមែនមកពីសមាជិកនៃក្រុមជំនុំនោះទេ ប៉ុន្តែគឺមកពីព្រះសិរសា ព្រះគ្រិស្តយេស៊ូដែលជាព្រះបុត្រារបស់ព្រះជាម្ចាស់ឯណោះវិញ។

ដូច្នេះ ក្រុមជំនុំគឺជាការប្រកបរួបរួមគ្នានៃមនុស្សមានបាបដែលបានប្រោះលោះ ដោយព្រះសង្គ្រោះតែមួយ ដែលបង្កើតឡើងដោយព្រះជាម្ចាស់។ ការប្រកបរួបរួមនៃអ្នកជឿនេះ គឺមានភាពតែមួយ ព្រោះសមាជិកគ្រប់រូបគឺសុទ្ធតែជាចំណែកមួយនៅក្នុងគ្នាទៅវិញទៅមក និងនៅក្នុងព្រះគ្រិស្តផង តាមរយៈការរួមមកតែមួយដែលព្រះវិញ្ញាណដ៏វិសុទ្ធបានប្រទានមក។

កំណត់ត្រាគម្ពីរសម្ព័ន្ធមេត្រីថ្មី បានកត់ត្រាថា អ្នកជឿថ្មីត្រូវបានគេជំរុញឲ្យធ្វើតាមការទទួលស្គាល់ព្រះយេស៊ូជាព្រះអម្ចាស់របស់ពួកគេជាមួយនឹងការជ្រមុជទឹក ដែលជារូបភាពបញ្ជាក់ពីការរួបរួមរបស់ពួកគេជាមួយព្រះគ្រិស្ត (សូមមើលនៅក្នុងគម្ពីរកិច្ចការ ២:៣៨; ៨:១២-១៣; ៩:១-១៩; ១០:៤៧- ៤៨)។ អ្នកជឿថ្មី ដែលបង្កើតបានជាក្រុមជំនុំតាមតំបន់ និង ដែលជាទិដ្ឋភាពនៃក្រុមជំនុំសាកល មានលក្ខណសម្បត្តិដូចតទៅ៖

១. ពួកគេគឺជាអ្នកជឿដ៏ពិត លើព្រះយេស៊ូ។
២. ពួកគេធ្វើតាមការទទួលស្គាល់ជំនឿរបស់ពួកគេ ជាមួយនឹងការជ្រមុជទឹក។
៣. ពួកគេត្រូវបានរៀបចំឲ្យក្លាយទៅជាសហគមន៍ដែលមានការប្រកបរួបរួមគ្នា ឲ្យបានឆាប់តាមតែអាចធ្វើទៅបាន។ (ចូរប្រៀបធៀបគម្ពីរកិច្ចការ ១៣:៤៣ ជាមួយនឹង ១៤:២៣)
៤. ពួកគេមានគោលបំណងមួយដែលខុសពីគេ៖ គឺដើម្បីចូលរួមជាមួយគ្នា ក្នុងការថ្វាយបង្គំរួម និង ធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

### *លំហាត់អនុវត្តន៍*

២ ចូរគូសរង្វង់ជុំវិញអក្សរ នៅខាងមុខចម្លើយនីមួយៗដែលជាឃ្លាបំពេញយ៉ាងត្រឹមត្រូវ សម្រាប់ប្រយោគដូចតទៅនេះ៖ ការប្រើប្រាស់ពាក្យថា *ក្រុមជំនុំ* នៅក្នុងព្រះគម្ពីរ បានរួមបញ្ចូលគំនិតនិយាយពី

ក) អគារមួយខ្នង ដែលមនុស្សជួបជុំគ្នាដើម្បីថ្វាយបង្គំព្រះជាម្ចាស់។

ខ) ការជំនុំមនុស្សរបស់ព្រះជាម្ចាស់ ដែលជួបគ្នា និង ចែកចាយពីជំនឿដូចគ្នា និង ភាពស្មោះស្ម័គ្រដូចគ្នា ចំពោះព្រះយេស៊ូគ្រិស្ត។

គ) ការប្រកបគ្នាដែលត្រូវបានបង្កើតឡើងដោយព្រះជាម្ចាស់ នៃអ្នកជឿដែលជឿទុកចិត្តលើព្រះសង្គ្រោះដូចគ្នា និង ជាអ្នកដែលមានការរួបរួម ជាមួយគ្នាទៅវិញទៅមក ក៏ដោយសារតែការរួបរួមរបស់ពួកគេជាមួយនឹងទ្រង់។

ឃ) ក្រុមសាសនា ស្ថាប័ន ឬ និកាយគ្រប់ប្រភេទ គ្រប់ទំហំ។

ង) សហគមន៍នៅទូទាំងពិភពលោកទាំងមូល នៃអ្នកជឿដែលបានទទួលស្គាល់ជំនឿដូចគ្នាទៅលើព្រះជាម្ចាស់ និង ទទួលស្គាល់ភាពជាព្រះអម្ចាស់របស់ព្រះយេស៊ូគ្រិស្ត។

## ខ. ពេលដែលក្រុមជំនុំចាប់ផ្តើម

**វត្ថុបំណងទី២.** *ប្រាប់អំពីភស្តុតាងនៅក្នុងព្រះគម្ពីរចំនួនពីរយ៉ាង ដែលបង្ហាញពីពេលដែលក្រុមជំនុំចាប់ផ្តើមកើតមានឡើង និង ធ្វើការរៀបរាប់អំពីសកម្មភាពទាំងប្រាំពីរយ៉ាងរបស់អ្នកជឿកាលពីជំនាន់មុន។*

គំនិតដែលនិយាយអំពីសហគមន៍នៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ គឺត្រូវបានគេឃើញមាននៅក្នុងគម្ពីរសម្ពន្ធមេត្រីចាស់ នៅក្នុងព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ដែលថាក្រុមគ្រួសារលោកអប្រាហាំ នឹងក្លាយទៅជាមូលហេតុដែលធ្វើឲ្យផែនដីបានចម្រើនឡើង(គម្ពីរលោកុប្បត្តិ ១២:១-៣)។ ព្រះបន្ទូលសន្យានោះត្រូវបានបញ្ជាក់នៅក្នុងពេលដែលព្រះជាម្ចាស់ប្រោសលោះប្រជាជនអ៊ីស្រាអែល ពីចំណងទាសករពីស្រុកអេស៊ីប។ បន្ទាប់មកគោលគំនិត នៃសហគមន៍ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ក៏បានកាន់តែត្រូវគេផ្តោតយ៉ាងច្បាស់ថែមទៀតនៅពេលដែល ទំនួលខុសត្រូវ និង ព្រះពរដែលមាននៅក្នុងការសន្យារវាងព្រះជាម្ចាស់ និង លោកអប្រាហាំ ត្រូវបានបញ្ជាក់បង្ហាញកាន់យ៉ាងច្បាស់ឡើង (ចូលប្រៀបធៀបគម្ពីរនិក្ខមនំ ១៩:៤-៦ ជាមួយនឹង គម្ពីរលោកុប្បត្តិ ២២:១៧-១៨)។

ប៉ុន្តែនៅក្នុងប្រវត្តិសាស្ត្រគម្ពីរសម្ព័ន្ធមេត្រីចាស់ ថ្លែងថាសាសន៍អ៊ីស្រាអែលបានបរាជ័យក្នុងបេសកកម្មរបស់គេ ក្នុងការឲ្យពរទៅដល់ផែនដីតាមរយៈទីបន្ទាល់ និង គំរូរបស់គេ។ ទោះបីជា សហគមន៍នៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់ បានមានវត្តមាននៅក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់យ៉ាងណាក្តី ក៏ពួកគេនៅតែមិនសម្រេចបាននូវគោលបំណងដែលបម្រុងសម្រាប់ពួកគេដែរ។ ប៉ុន្តែបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ក្នុងការត្រាស់ហៅប្រជារាស្ត្ររបស់ទ្រង់ចេញពីលោកីយ៍ ដើម្បីប្រោសលោះពួកគេពីអំពើបាប និង ដើម្បីប្រទានសេចក្តីសង្គ្រោះឲ្យពួកគេគឺមិនទាន់បរាជ័យនៅឡើយទេ។ បំណងព្រះហឫទ័យនេះ នឹងអាច

សម្រេចបានតាមរយៈការសុគត និង ការមានព្រះជន្មរស់ឡើងវិញ របស់ព្រះយេស៊ូ ជាបុត្រជាទីស្រឡាញ់របស់ព្រះជាម្ចាស់។

ព្រះយេស៊ូបានណែនាំផ្នត់គំនិត នៃក្រុមជំនុំដែលជាសហគមន៍ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ នៅក្នុងពេលដែលទ្រង់ធ្វើព័ន្ធកិច្ចនៅលើផែនដី។ ទ្រង់បានមានព្រះបន្ទូល ដោយប្រើប្រយោគអនាគតកាលថា៖ "ខ្ញុំនឹងសង់ក្រុមជំនុំ*របស់ខ្ញុំ" (គម្ពីរម៉ាថាយ ១៦:១៨)។ លោកប៉ូលបង្ហាញនៅក្នុងគម្ពីរអេភេសូ ១:១៩-២៣ ថា ការមានព្រះជន្មរស់ឡើងវិញ និង ការយាងត្រឡប់ទៅស្ថានសួគ៌វិញរបស់ព្រះអម្ចាស់នៃយើង បានកើតមានឡើងតាំងពីមុនពេលដែលក្រុមជំនុំអាចបង្កើតឡើងទៅទៀត ហើយព្រះយេស៊ូក៏ត្រូវបានលើកជាព្រះសិរសារបស់សហគមន៍ដែលបានប្រោសលោះ ដែល "ព្រះអង្គបានសំដែងមហិទ្ធិឫទ្ធិនេះ ដោយប្រោសព្រះគ្រិស្តអោយមានព្រះជន្មរស់ឡើងវិញ និងអោយគង់នៅខាងស្តាំព្រះអង្គនៅស្ថានបរមសុខ។ ....ព្រះជាម្ចាស់បានបង្ក្រាបអ្វីៗទាំងអស់ អោយនៅក្រោមព្រះបាទារបស់ព្រះគ្រិស្ត ព្រមទាំងប្រទានអោយព្រះអង្គគង់នៅលើអ្វីៗទាំងអស់ ធ្វើជាសិរសាលើក្រុមជំនុំ ដែលជាព្រះកាយរបស់ព្រះអង្គ។" (ខ២០, ២២- ២៣)

ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រិស្ត និង ការយាងឡើងទៅស្ថានសួគ៌ ក៏ជាការចាំបាច់ ដើម្បីឲ្យទ្រង់បាន ធ្វើការដឹកនាំ ក្នុងឋានៈជាបូជាចារ្យជាន់ខ្ពស់ដ៏អស់កល្បជានិច្ច សម្រាប់ប្រជារាស្ត្ររបស់ទ្រង់ (ក្រុមជំនុំ)។ លើសពីនេះទៅទៀត ទ្រង់ក៏អាចប្រទានឲ្យ ក្រុមជំនុំនូវព្រះអំណោយទាន ដែលចាំបាច់សម្រាប់ ការប្រតិបត្តិរបស់ពួកគេ (សូមមើលគម្ពីរហេប្រឺ ៤:១៤-១៦; ៧:២៥ គម្ពីរអេភេសូ ៤:៧-១២)។

## លំហាត់អនុវត្តន៍

៣ ដោយផ្អែកទៅលើបទគម្ពីរសម្ព័ន្ធមេត្រីថ្មីនៅខាងលើ តើប្រយោគមួយណាជាចម្លើយត្រឹមត្រូវ?

ក) ព្រះគម្ពីរបង្ហាញថាក្រុមជំនុំ គឺត្រូវបានបង្កើតឡើងដោយព្រះយេស៊ូ នៅអំឡុងពេលទ្រង់ធ្វើព័ន្ធកិច្ចរបស់ទ្រង់នៅលើផែនដី។

ខ) បទគម្ពីរផ្តល់នូវភស្តុតាងដែលបង្ហាញថា ការសុគត ការមានព្រះជន្មរស់ឡើងវិញ និង ការយាងត្រឡប់ទៅស្ថានសួគ៌របស់ទ្រង់កើតឡើងមុនពេលដែលទ្រង់អាចបង្កើតក្រុមជំនុំរបស់ទ្រង់មកម្ល៉េះ។

---

តាមទម្លាប់ គេបានចាត់ទុកថាក្រុមជំនុំ បានចាប់ផ្តើមជាផ្លូវការនៅថ្ងៃបុណ្យថ្ងៃទីហាសិប ទោះបីជាអ្នកជឿបានជួបជុំគ្នាតាំងពីមុនពេលនេះទៅទៀត។ សូមមើលទៅលើភស្តុតាង៖

១. មុនពេលទ្រង់យាងត្រឡប់ទៅស្ថានសួគ៌វិញ ព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់ពួកសាវ័ករបស់ទ្រង់ថា៖ "មិនអោយចេញទៅណាឆ្ងាយពីក្រុងយេរូសាឡឹមឡើយ «គឺត្រូវរង់ចាំទទួលព្រះវិញ្ញាណ តាមព្រះបន្ទូលសន្យារបស់ព្រះបិតា ដូចខ្ញុំបានប្រាប់អ្នករាល់គ្នារួចមកហើយថា លោកយ៉ូហានបានធ្វើពិធីជ្រមុជ*អោយគេក្នុងទឹក ប៉ុន្តែ នៅប៉ុន្មានថ្ងៃទៀត អ្នករាល់គ្នានឹងទទួលពិធីជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធវិញ" ។ (គម្ពីរកិច្ចការ១:៤-៥ ហើយសូមអាននៅគម្ពីរយ៉ូហាន ១:៤-១២;១៦:៧-៨, ១៣-១៥)។

២. បន្ទាប់មកព្រះយេស៊ូក៏បានសន្យាថា កាលណាពួកគេបានជ្រមុជក្នុងព្រះវិញ្ញាណដ៏វិសុទ្ធហើយ សាវ័កនឹងក្លាយជាសក្ខីភាពដែលមានអំណាចអស្ចារ្យ សម្រាប់ដំណឹងល្អ ទាំងនៅទីជិតនិងទីឆ្ងាយ។ (គម្ពីរកិច្ចការ ១:៨)។

៣. ដោយធ្វើតាមព្រះបន្ទូលរបស់ព្រះយេស៊ូ ពួកសាវ័ក និង អ្នកជឿដែលកំពុងអធិស្ឋាននៅបន្ទប់ខាងលើ ក៏ត្រូវបានទទួលការជ្រមុជនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ ដែលបានយាងចុះមកនៅក្នុងថ្ងៃបុណ្យថ្ងៃទីហាសិប និង  បានសង់ដំណាក់របស់ទ្រង់នៅក្នុងជីវិតរបស់ពួកគេម្នាក់ (គម្ពីរកិច្ចការ ២:១-៤ ប្រៀបធៀបជាមួយនឹងគម្ពីរយ៉ូហាន ៧:៣៧-៣៩ ជាមួយនឹង ១៤:១៧)។

៤. លើសពីនេះទៅទៀត នៅក្នុងថ្ងៃនោះដែរ មានមនុស្សចំនួន៣០០០ នាក់បានឆ្លើយទៅនឹងសារដំណឹងល្អ និង បានក្លាយទៅជាទិដ្ឋភាពមួយនៃសហគមន៍អ្នកជឿ។ ដូច្នេះ ក្រុមជំនុំក៏ត្រូវបានបង្កើតឡើង និង ចាប់ផ្តើមមានតួនាទីជាសហគមន៍សម្រាប់ ការសរសើរតម្កើង សម្រាប់បីបាច់ថែរក្សា និង ផ្សាព្វផ្សាយដំណឹងល្អ ឬ ធ្វើជាសក្ខីភាព។

នោះ ការយាងមកដល់របស់ព្រះវិញ្ញាណដ៏វិសុទ្ធ បានកំណត់សំគាល់ទីចាប់ផ្តើមនៃសករាជថ្មី ដែលអ្នកជឿទទួលបានឫទ្ធានុភាពពីព្រះជាម្ចាស់ ដើម្បីធ្វើបន្ទាល់អំពីព្រះគុណនៃការសង្គ្រោះព្រះជាម្ចាស់ និង ការត្រាស់សម្រាប់សេចក្តីសង្គ្រោះជាសាកលរបស់ទ្រង់។ កណ្ឌគម្ពីរកិច្ចការ ប្រកាសថា ចាប់តាំងពីថ្ងៃដំបូងចាប់ផ្តើមដំបូងមក ពួកអ្នកជឿបានធ្វើសកម្មភាពជាគ្រួសារ ឬ សហព័ន្ធមួយរួចទៅហើយ។ ខាងក្រោមនេះ គឺលក្ខណសម្បត្តិខ្លះៗរបស់អ្នកជឿទាំងនោះ និង លក្ខណសម្បត្តិនៃក្រុមជំនុំដំបូងបង្អស់៖

១. ពួកគេមានខ្នាតគំរូគោលលទ្ធិមួយ ដែលជាសេចក្តីបង្រៀនរបស់ពួកសាវ័ក (គម្ពីរកិច្ចការ ២:៤២)។

២. ពួកគេមានសម្ព័ន្ធភាពជាមួយអ្នកជឿដទៃផ្សេងទៀត (គម្ពីរកិច្ចការ ២:៤២)។

៣. ពួកគេប្រតិបត្តិតាមបទបញ្ជា នៃការជ្រមុជទឹក និង ពិធីលាងព្រះអម្ចាស់ (គម្ពីរកិច្ចការ ២:៤១-៤២,៤៧; សូមមើលគម្ពីរម៉ាថាយ ២៨:១៩ គម្ពីរ១កូរិនថូស ១១:២៣-២៦)។

៤. ពួកគេបានជួបជុំគ្នា ដើម្បីធ្វើការថ្វាយបង្គំ និង ការអធិស្ឋានបើកចំហជាសាធារណៈ (គម្ពីរកិច្ចការ ២:៤៦; ៤:២៣-៣១)។

៥. ពួកគេជួយដល់មនុស្សខ្វះខាត (គម្ពីរកិច្ចការ ៤:៣២-៣៥; ៦:១-៧)។

៦. ពួកគេចាត់តាំងមនុស្ស ឲ្យទៅកន្លែងផ្សេងៗដើម្បីចែកចាយដំណឹងល្អ និង បង្កើតសហគមន៍អ្នកជឿថ្មី (គម្ពីរកិច្ចការ៨:១៤-១៧; ១១:២២)។

៧. ពួកគេសិក្សាអំពីទិដ្ឋភាពមួយនៃការចែកចាយដំណឹងល្អ បូករួមទាំងមនុស្សដែលដំណឹងល្អនៅបានទៅដល់ និង ការប្រតិបត្តិរបស់គ្រិស្តបរិស័ទថ្មីថ្មោង ហើយពួកគេបានបង្កើតខ្នាតគំរូគោលលទ្ធិសំខាន់ចាំបាច់សម្រាប់គ្រិស្តបរិស័ទ (គម្ពីរកិច្ចការ១១:១-៣, ១៨; ១៥:៤-៣៥)។

## *លំហាត់អនុវត្តន៍*

៤ ចូរឆ្លើយដាក់នៅក្នុងសៀវភៅកត់ត្រារបស់អ្នក នូវរឿងពីរយ៉ាងដែលបានកើតឡើងនៅក្នុងថ្ងៃបុណ្យថ្ងៃទីហាសិប ដែលបានផ្តល់ជាភស្តុតាងបញ្ជាក់ថា ក្រុមជំនុំបានចាប់ផ្តើមនៅក្នុងថ្ងៃនោះ មិនយូរប៉ុន្មានក្រោយពេលដែលព្រះយេស៊ូបានយាងត្រឡប់ទៅស្ថានសួគ៌វិញ (សូមមើលគម្ពីរកិច្ចការជំពូក២)។

៥ ចូររៀបរាប់ ចេញពីការចងចាំរបស់អ្នក នូវសកម្មភាពទាំងប្រាំពីរយ៉ាងរបស់អ្នកជឿដំបូងបង្អស់ ដែលបានផ្តល់ឲ្យពួកគេនូវលក្ខណសម្បត្តិនៃក្រុមជំនុំ ឬ រូបភាពមួយដែលរួបរួមគ្នា។ ចូរសរសេរចម្លើយរបស់អ្នកនៅក្នុងសៀវភៅកត់ត្រារបស់អ្នក ហើយប្រៀបធៀបចម្លើយរបស់អ្នកជាមួយនឹងតារាងដែលយើងបានផ្តល់ជូននៅចំណុចខាងលើនេះ។ តើការរៀបរាប់នេះ ស្រដៀងទៅនឹងសកម្មភាពនៃក្រុមជំនុំតាមតំបន់របស់អ្នកដែរឬទេ?

# គ. លក្ខណៈរបស់ក្រុមជំនុំ

**វត្ថុបំណងទី៣.** *ស្គាល់លក្ខណៈដែលរៀបរាប់ពីនិស្ស័យរបស់ក្រុមជំនុំ។*

នៅពេលដែលមនុស្សទទួលស្គាល់ព្រះគ្រិស្តជាព្រះអម្ចាស់ ព្រះវិញ្ញាណដ៏វិសុទ្ធក៏ប្រទានការសង្គ្រោះសម្រាប់ពួកគេ ព្រមទាំងភ្ជាប់ពួកគេជាមួយនឹងអស់អ្នកជឿនៅក្នុងសហគមន៍មួយដែលយើងហៅថាក្រុមជំនុំ ឬ *ព្រះកាយរបស់ព្រះគ្រិស្ត* នោះផងដែរ។ នៅក្នុងព្រះគម្ពីរ ក្រុមជំនុំត្រូវបានប្រៀបប្រដូចទៅនឹងព្រះកាយ កូនក្រមុំ អគារព្រះវិហារ មែកទំពាំងបាយជូរ និង ហ្វូងចៀម។ និមិត្តសញ្ញាទាំងនេះ គឺត្រូវបានយកមកប្រើប្រាស់ជាមួយនឹងបុគ្គលអ្នកជឿផង ក្រុមជំនុំតាមតំបន់ និងក្រុមជំនុំសាកលផងដែរ។

## *លំហាត់អនុវត្តន៍*

៦ ចូរផ្គូផ្គងពាក្យ (ខាងស្តាំ) ទៅជាមួយនឹងបទគម្ពីរដែលរៀបរាប់អំពីពាក្យនោះ (ខាងឆ្វេង)។

| | | | |
|---|---|---|---|
| .........ក) | គម្ពីរលូកា ១៥:៤-១០ (ហ្វូងចៀម) | ១) | បុគ្គលអ្នកជឿម្នាក់ៗ |
| .........ខ) | គម្ពីរ២កូរិនថូស ១១:២ (កូនក្រមុំ) | ២) | ក្រុមជំនុំតាមតំបន់ |
| .........គ) | គម្ពីរ១កូរិនថូស ៣:១៦-១៧ (អគារព្រះវិហារ) | ៣) | ក្រុមជំនុំសាកល |
| .........ឃ) | គម្ពីរអេភេសូ ១:២២-២៣ (ព្រះកាយ) | | |
| .........ង) | គម្ពីរហេព្រើ ១៣:២០ (ហ្វូងចៀម) | | |
| .........ច) | គម្ពីរយ៉ូហាន ១៥:១-៥ (មែកទំពាំងបាយជូរ) | | |

លំហាត់នេះបង្ហាញអ្វីម្យ៉ាងអំពីលក្ខណៈរបស់ក្រុមជំនុំ។ នៅពេលដែលបុគ្គលអ្នកជឿម្នាក់ នៅតែឯងគេមិនអាចបង្កើតជាក្រុមជំនុំបានឡើយ ព្រោះក្រុមជំនុំគឺជាតួខ្លួនមួយដែលផ្គុំឡើងពីបុគ្គលអ្នកជឿជាច្រើននាក់។ ប្រសិនបើយើងសំគាល់ក្រុមជំនុំ ថាជាគ្រឹះស្ថាន ឬ ស្ថាប័នមួយ យើងនឹងវង្វេងយ៉ាងឆាប់រហ័សលែងដឹងថានេះគឺជាសហគមន៍នៃអ្នកជឿ ជាអ្នកជឿដែលបាន ចូលមករកគ្នានៅក្នុងទំនាក់ទំនងយ៉ាង

ស្និតរមួត ជាមួយគ្នាទៅវិញទៅមក ដែលជាលទ្ធផលបានមកទំនាក់ផ្ទាល់ខ្លួនរបស់ពួកគេជាមួយព្រះគ្រិស្ត។ អ្នកជឿទាំងនេះ បម្រើគ្នាទៅវិញទៅមក ស្រឡាញ់គ្នាទៅវិញទៅមក និង ជួយគ្នាទៅវិញទៅមកនៅក្នុងដំណើរជាគ្រិស្តបរិស័ទ។ ដូច្នេះលក្ខណៈ របស់ក្រុមជំនុំអាចត្រូវបានបកស្រាយបានតាមរបៀបពីរយ៉ាង។ ទីមួយ គឺមានជាប់ទាក់ទងទៅនឹងទំនងទំនងរបស់អ្នកជឿជាមួយគ្នាទៅវិញទៅមក។ ទីពីរ គឺការបង្ហាញឲ្យឃើញ នូវការរួបរួមរបស់អ្នកជឿជាមួយនឹងព្រះគ្រិស្ត។

១. *ក្រុមជំនុំ ជាប់ទាក់ទងរបស់អ្នកជឿជាមួយគ្នាទៅវិញទៅមក និង ទៅជាមួយព្រះគ្រិស្ត។*

នៅពេលមនុស្សមានបាបប្រឈមមុខជាមួយនឹងដំណឹងល្អ ពួកគេគឺឈរតែឯងនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់។ ជម្រើសរបស់ពួកគេ នៅក្នុងការទទួល ឬ ច្រានចោលដំណឹងល្អ គឺជាជម្រើសផ្ទាល់ខ្លួនរបស់ពួកគេ ដែលមានតែគេម្នាក់ឯងប៉ុណ្ណោះដែលធ្វើការសម្រេចបាន។ មិនថាជម្រើសរបស់ពួកគេគឺជាអ្វី ពួកគេនឹងឃើញថា មានអ្នកដទៃផ្សេងទៀតក៏បានធ្វើការជ្រើសរើសដូចគេដែរ។ ដូច្នេះទោះបីជាសេចក្ដីសង្គ្រោះគឺជាកិច្ចការផ្ទាល់ខ្លួន ប៉ុន្តែការនេះនៅតែមិនមែនជាបញ្ហាបុគ្គលនោះទេ។ ការសង្គ្រោះនាំយើងឲ្យបានចូលទៅក្នុងទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះយេស៊ូគ្រិស្ត និងជាមួយអ្នកជឿដទៃផ្សេងទៀត។ ទាំងពីរនេះគឺសុទ្ធតែមានភាពចាំបាច់នៅក្នុងការលូតលាស់ខាងវិញ្ញាណ និង ការអភិវឌ្ឍលក្ខណៈដូចជាព្រះគ្រិស្ត នៅក្នុងបុគ្គលអ្នកជឿម្នាក់ៗ។

លោកប៉ូលបាននិយាយអំពីទំនាក់ទំនងជាមួយនឹងព្រះយេស៊ូគ្រិស្ត ដែលអ្នកជឿបានចូលខ្លួនទៅក្នុងទំនាក់ទំនងនោះក្នុងពេលដែលមានសេចក្ដីសង្គ្រោះ៖ "ខ្ញុំបានជាប់ឆ្កាងរួមជាមួយព្រះគ្រិស្តដូច្នេះ មិនមែនខ្ញុំទៀតទេដែលរស់នៅ គឺព្រះគ្រិស្តទេតើ ដែលមានព្រះជន្មរស់នៅក្នុងរូបកាយខ្ញុំ។ រីឯជីវិតដែលខ្ញុំរស់ជាមនុស្សនាបច្ចុប្បន្នកាលនេះ ខ្ញុំរស់ដោយមានជំនឿទៅលើព្រះបុត្រារបស់ព្រះជាម្ចាស់ ដែលបានស្រឡាញ់ខ្ញុំ និងបានបូជាព្រះជន្មសំរាប់ខ្ញុំ។ (គម្ពីរកាឡាទី ២:២០) ។ លោកបានថ្លែងអំពីទំនាក់ទំនងរបស់អ្នកជឿជាមួយអ្នកជឿដទៃទៀត នៅពេលដែលលោកមានប្រសាសន៍ថា "យើងជាសរីរាង្គរបស់គ្នាទៅវិញទៅមក។" (គម្ពីរអេភេសូ ៤:២៥)។ នោះគឺមានន័យថា អ្នកជឿទាំងអស់ រួមជាមួយគ្នា បង្កើតបានជាក្រុមជំនុំ។

ដូច្នេះ បើមើលចេញពីជ្រុងមួយទៅ អ្នកជឿម្នាក់ គឺជាបុគ្គលដែលរស់នៅក្នុងទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះគ្រិស្ត  រួមជាមួយនឹងទំនួលខុសត្រូវផ្ទាល់ខ្លួន ទៅលើជីវិតជាគ្រិស្តបរិស័ទរបស់គាត់។ តែបើមើលចេញពីជ្រុងមួយទៀត អ្នកជឿទាំងអស់លាយឡំចូលគ្នា នៅក្នុងការរួបរួមខាងវិញ្ញាណមួយ ដូច្នេះហើយពួកគេក៏មានទំនាក់ទំនងជាមួយព្រះគ្រិស្ត ដែលមានទំនួលខុសត្រូវ*រួមគ្នា*ទៅចំពោះទ្រង់។

## *លំហាត់អនុវត្តន៍*

៧ បទគម្ពីរបានប្រៀបធៀបទំនាក់ទំនងរវាងព្រះគ្រិស្ត និង ក្រុមជំនុំ ទៅជាមួយនឹងព្រះសិរសា និង ព្រះកាយ។ ចូរអានគម្ពីរ ១កូរិនថូស ១២: ១២-២៧ គម្ពីរអេភេសូ ១:២២-២៣; ៤:៧-១៦ និង គម្ពីរកូឡូស ១:១៨ ។ ដោយផ្អែកទៅលើបទគម្ពីរទាំងនេះ ចូរគូសរង្វង់ជុំវិញអក្សរដែលនៅខាងមុខប្រយោគត្រឹមត្រូវ ដែលនិយាយអំពីព្រះកាយរបស់ព្រះគ្រិស្ត។

ក) នៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត មានទិដ្ឋភាពជាច្រើន។

ខ) ទិដ្ឋភាពខ្លះនៅក្នុងព្រះកាយ គឺមិនសូវជាសំខាន់ដូចជាទិដ្ឋភាពដទៃផ្សេងទៀតទេ។

គ) អ្នកជឿតែម្នាក់អាចលូតលាស់ នៅក្នុងភាពពេញវ័យនៃគ្រិស្តបរិស័ទដោយ មិនបាច់ជាសមាជិកដ៏សកម្មនៅក្នុងព្រះកាយរបស់ព្រះគ្រិស្តឡើយ។

ឃ) អ្នកជឿម្នាក់ៗ គឺជាទិដ្ឋភាពមួយនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត។

ង) ព្រះគ្រិស្តគឺជាព្រះសិរសាលើគ្រប់អ្វីៗទាំងអស់សម្រាប់ក្រុមជំនុំ ដែលជាព្រះកាយរបស់ទ្រង់។

ច) អ្នកជឿម្នាក់ៗគឺជាទំនួលខុសត្រូវរបស់ព្រះគ្រិស្តតែមួយអង្គឯង។

ឆ) ប្រសិនបើសមាជិកនៃព្រះកាយ រងទុក្ខ សមាជិកដទៃនឹងទទួលអារម្មណ៍ឈឺចាប់ និងទុក្ខសោកជាមួយពួកគេដែរ។

ជ) ព្រះអំណោយទានដែលព្រះគ្រិស្ត បានប្រទានទៅកាន់ក្រុមជំនុំ គឺចាំបាច់ ដើម្បីឲ្យសមាជិកម្នាក់ៗអាចទទួលបាននូវការលូតលាស់ផ្ទាល់ខ្លួន។

---

បទគម្ពីរទាំងនេះ បង្រៀនយើងថាវាមិនមែនជារឿងចៃដន្យ ដែលថានៅក្នុងគម្ពីរសម្ព័ន្ធមេត្រីថ្មី ជីវិតរបស់គ្រិស្តគឺជាបទពិសោធន៍រួមគ្នាមួយ។ អ្នកជឿថ្មីថ្មោងគឺត្រូវបានទាញឲ្យចូលគ្នាបានយ៉ាងរលូននៅក្នុងការថ្វាយបង្គំ ការប្រកបគ្នា និង ការធ្វើសក្ខីភាព។ តាមរយៈការកើតជាថ្មី និស្ស័យចាស់ដ៏អាត្មានិយមរបស់ពួកគេ ត្រូវបានដកចេញ ហើយពួកគេបានក្លាយទៅជាទិដ្ឋភាពមួយនៃសហគមន៍ដែលចេះ ខ្វល់ខ្វាយពីគ្នា និង ចែករំលែកគ្នា។

ព្រះគម្ពីរបានបង្ហាញយ៉ាងច្បាស់ថា ការដើរតួជាដៃគូជាមួយអ្នកជឿដទៃនៅក្នុងព្រះកាយ ដែលចាំឆ្លើយតបទៅនឹងព្រះសិរសា គឺជាកិច្ចការមួយដែលទាមទារការយកចិត្តទុកដាក់ខ្លាំងណាស់។ តាមពិតទៅគឺថា ពួកយើងម្នាក់ៗមានទំនួលខុសត្រូវដែលលើសពីការជ្រើសរើសផ្ទាល់ខ្លួនរបស់យើងទៅទៀត ដែលនោះគឺជាទំនាក់ទំនងផ្ទាល់ខ្លួនរបស់យើងជាមួយនឹងព្រះសិរសា ឬតម្លៃផ្ទាល់ខ្លួនរបស់យើង។ ឥឡូវនេះយើងមានតួនាទីជាទិដ្ឋភាពមួយនៃព្រះកាយរបស់ព្រះគ្រិស្ត។ នោះហើយជាមូលហេតុដែលលោកប៉ូលបានខ្វល់ខ្វាយនឹងក្រុមជំនុំនៅក្រុងកូរិនថូសជាខ្លាំង៖

> បងប្អូនអើយ ខ្ញុំសូមទូន្មានបងប្អូនក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត*ជាព្រះអម្ចាស់នៃយើងថា ចូរមានចិត្តគំនិតតែមួយ កុំបាក់បែកគ្នាឡើយ ត្រូវចុះសំរុងគ្នាទាំងស្រុងដោយមានគំនិតតែមួយ និងមានយោបល់តែមួយ។ (គម្ពីរ១កូរិនថូស ១:១០)។

ក្នុងនាមជាទិដ្ឋភាពមួយនៃក្រុមជំនុំ ដែលជាសហព័ន្ធមួយដែលមានទំនាក់ទំនងទៅជាមួយនឹងព្រះគ្រិស្ត ខ្ញុំត្រូវមានការប្រាស្រ័យជាមួយនឹងដៃគូផ្សេងទៀតនៅក្នុងព្រះគ្រិស្ត បើសិនខ្ញុំចង់ប្រាស្រ័យជាមួយនឹងទ្រង់។ បន្ទាប់មក ដូចដែលបានបង្ហាញនៅក្នុងបទគម្ពីរ ក្រុមជំនុំគឺជា*មនុស្ស*។ មនុស្សទាំងនេះ មានទំនាក់ទំនងជាមួយនឹងព្រះគ្រិស្ត ហើយតាមរយៈទ្រង់ពួកគេមានទំនាក់ទំនងរវាងគ្នាទៅវិញទៅមក។

២. *ក្រុមជំនុំគឺជាការស្ដែងចេញដែលអាចមើលឃើញនឹងភ្នែក នៃការរួបរួមរបស់អ្នកជឿ ជាមួយនឹងព្រះគ្រិស្ដ។*

ព្រះជាម្ចាស់បានរចនា ក្រុមជំនុំតាមរបៀបមួយដែល ធ្វើឲ្យមានលក្ខណៈអាចឲ្យគេដឹងបានតាមរយៈទំនាក់ទំនងរបស់អ្នកជឿ។ ដោយសារតែ ទំនាក់ទំនងរបស់យើងជាមួយនឹងព្រះគ្រិស្ដ គឺជាបទពិសោធន៍ខាងវិញ្ញាណ នោះមធ្យោបាយតែមួយគត់ដែលអាចធ្វើឲ្យទំនាក់ទំនងនោះក្លាយជាសេចក្ដីពិតដែលគេអាចមើលឃើញ គឺមានតែតាមរយៈជីវិតរបស់យើងតែប៉ុណ្ណោះ។ យើងអាច ហើយក៏បានធ្វើការប្រាប់អ្នកដទៃអំពីអ្វីដែលយើងជឿ។ ប្រសិនបើជីវិតរបស់យើង គឺត្រូវបានសំគាល់ដោយសេចក្ដីមេត្តា ចិត្តសប្បុរស និង សេចក្ដីស្រឡាញ់ដ៏ពិតរបស់គ្រិស្ដបរិស័ទ នោះមនុស្សម្នានឹងយល់ពីគំនិតដែលថា ទំនាក់ទំនងដែលមើលមិនឃើញរបស់យើងជាមួយព្រះគ្រិស្ដ គឺមានពិតប្រាកដ។ ទោះជាយ៉ាងណា ប្រសិនបើយើងមិនរស់នៅដោយផ្អែកទៅលើ ទីបន្ទាល់ដែលយើងបានថ្លែង នោះអ្នកដែលមិនមែនជាគ្រិស្ដបរិស័ទអាចនឹងនិយាយថា៖ "ទង្វើរបស់អ្នក ស្ដែងចេញមកយ៉ាងខ្លាំងដែលខ្ញុំមិនអាចស្ដាប់ឮអ្វីដែលអ្នកនិយាយនោះទេ!"

ការនេះក៏មានពិតផងដែរ នៅក្នុងជីវិតដែលរស់នៅរួមគ្នាក្នុងសហគមន៍នៃអ្នកជឿ។ ភាពពិតនៃទំនាក់ទំនងរវាងរូបកាយ (ក្រុមជំនុំ) និង សិរសារ (ព្រះគ្រិស្ដយេស៊ូ) គឺត្រូវបានឆ្លុះឲ្យឃើញនៅក្នុងជីវិតរបស់ក្រុមជំនុំ។ នោះគឺជាមូលហេតុដែលលោកប៉ូល ក្រើនរំឭកអ្នកជឿនៅក្រុងអេភេសូ ឲ្យ "ចូរបន្ទាបខ្លួនមានចិត្តស្លូតបូត និងចេះអត់ធ្មត់ ព្រមទាំងទ្រាំទ្រគ្នាទៅវិញទៅមកដោយសេចក្ដីស្រឡាញ់។ ចូរយកចិត្តទុកដាក់រក្សាឯកភាពដែលមកពីព្រះវិញ្ញាណ ដោយយកសេចក្ដីសុខសាន្ដធ្វើជាចំណងប្រាស្រ័យទាក់ទងគ្នា។ (គម្ពីរអេភេសូ ៤:២-៣)។

នៅក្នុងជំនាន់របស់លោកប៉ូល មានរនាំងដ៏ធំមួយនៅក្នុងសង្គម ដែលបានចែកផ្ដាច់សាសន៍យូដា និង សាសន៍ដទៃ ព្រមទាំងទាសករ និង អ្នកដែលកើតមកក្នុងសេរីភាព។ ក្រៅពីដំណឹងល្អ គ្មានមធ្យោបាយណាផ្សេងទៀតដែលអាចយកឈ្នះលើរនាំងទាំងនេះបានទេ ប៉ុន្តែនៅក្នុងគម្ពីរអេភេសូ ២:១១-២២ បកស្រាយថា តាមរយៈឈើឆ្កាងរបស់ព្រះគ្រិស្ដអ្វីៗទាំងអស់នេះ គឺត្រូវបានផ្លាស់ប្ដូរ។ ទ្រង់បានកំទេចរនាំងរវាងសាសន៍យូដា និងសាសន៍ដទៃ ហើយបានធ្វើឲ្យពួកគេក្លាយជា "បងប្អូនជាជនរួមជាតិជាមួយប្រជាជនដ៏វិសុទ្ធ* និងជាក្រុមគ្រួសាររបស់ព្រះជាម្ចាស់។" (ខ១៩)។ ទំនាក់ទំនងជាមួយនឹងព្រះគ្រិស្ដបានដកចេញ ភាពខុសគ្នានៅក្នុងសង្គម និង រួបរួមមនុស្សទាំងអស់ ដែលក្លាយជាទិដ្ឋភាពមួយនៅក្នុងក្រុមគ្រួសាររបស់ព្រះជាម្ចាស់។

ក្នុងនាមជាសមាជិកនៃព្រះកាយតែមួយ មនុស្សទាំងអស់ដែលមានប្រវត្តិសាស្ត្រក្នុងសង្គមផ្សេងៗពីគ្នា បានមករួបរួមគ្នា ខាងវិញ្ញាណ និង គោលបំណង (សូមមើលនៅក្នុងគម្ពីរភីលីព ២:២)។ ពួកគេត្រូវមានចិត្តសប្បុរស និង សេចក្ដីមេត្តាករុណាចំពោះគ្នាទៅវិញទៅមក។ ព្រះយេស៊ូបានប្រទានឲ្យការកំណត់មួយនេះ មានកម្រិតស្មើនឹង*បទបញ្ញាថ្មី* ៖ ខ្ញុំអោយបទបញ្ញាថ្មីដល់អ្នករាល់គ្នា គឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក។ អ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។ បើអ្នកស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់មុខជាដឹងថា អ្នករាល់គ្នាពិតជាសិស្ស*របស់ខ្ញុំមែន»។" (គម្ពីរយ៉ូហាន ១៣:៣៤-៣៥)។

ដូច្នេះយើងឃើញថា ទំនាក់ទំនងរបស់អ្នកជឿ គឺត្រូវបានសំគាល់ដោយ*សេចក្ដីស្រឡាញ់។*គោលការណ៍មួយនេះគឺមានសារសំខាន់ណាស់ ដែលអាចត្រូវបានយកទៅប្រើប្រាស់ជារង្វាស់ដ៏សុក្រឹតមួយ សម្រាប់កំណត់ទំនាក់ទំនងរបស់មនុស្សម្នាក់ជាមួយព្រះជាម្ចាស់៖ " អ្នកណាអះអាងថាខ្លួនស្ថិតនៅក្នុងពន្លឺ តែស្អប់បងប្អូន អ្នកនោះស្ថិតនៅក្នុងសេចក្ដីងងឹតនៅឡើយ" (គម្ពីរ១យ៉ូហាន ២:៩)។ លោកយ៉ូហានបានបន្តទៀតថា៖

> បើនរណាម្នាក់ពោលថា "ខ្ញុំស្រឡាញ់ព្រះជាម្ចាស់" តែស្អប់បងប្អូនរបស់ខ្លួន អ្នកនោះនិយាយកុហកហើយ។ អ្នកណាមិនស្រឡាញ់បងប្អូនដែលខ្លួនមើលឃើញ ក៏ពុំអាចស្រឡាញ់ព្រះជាម្ចាស់ដែលខ្លួនមើលពុំឃើញនោះបានដែរ។ យើងបានទទួលបទបញ្ជានេះពីព្រះអង្គថា «អ្នកណាស្រឡាញ់ព្រះជាម្ចាស់ អ្នកនោះក៏ត្រូវស្រឡាញ់បងប្អូនដែរ"។ (គម្ពីរ១យ៉ូហាន ៤:២០-២១)។

នេះគឺជាមូលហេតុដែលលោកប៉ូលស្ដីបន្ទោស ចំពោះភាពច្រណែន និង ជម្លោះរវាងគ្រិស្ដបរិស័ទនៅក្រុមកូរិនថូស ដែលបាននាំឲ្យពួកគេបែងចែកទៅជាក្រុមផ្សេងៗគ្នា ទាំងនិយាយថា "ខ្ញុំជាកូនចៅរបស់លោកប៉ូល!" ឬ "ខ្ញុំជាកូនចៅរបស់លោកអប៉ូឡូស!" (១កូរិនថូស ៣:៤)។ នេះមិនមែនជាឥរិយាបថរបស់គ្រិស្ដបរិស័ទនោះទេ ប៉ុន្តែវាឥរិយាបថរបស់ទារកដែលមិនទាក់ទងខាងវិញ្ញាណនោះទេ។ បទបញ្ជា និង គំរូទាំងនេះ ជួយយើងឲ្យឃើញថា ប្រសិនបើយើងមិនចុះសម្រុងគ្នានោះទេ យើងក៏មិនចុះសម្រុងជាមួយព្រះជាម្ចាស់ផងដែរ។

## *លំហាត់អនុវត្តន៍*

៨ (ចូរជ្រើសរើសចម្លើយដែលល្អបំផុត)។ លក្ខណៈរបស់ក្រុមជំនុំ ដែលជាសហគមន៍ខាងវិញ្ញាណមួយ អាចនឹងត្រូវចាត់ទុកថា

- ក) មនុស្សមួយក្រុម ដែលព្យាយាមមានការរួបរួមជាមួយគ្នាទៅវិញទៅមក។
- ខ) អ្នកជឿទាំងអស់ ដែលស្ថិតនៅក្នុងការរួបរួមមួយជាមួយព្រះគ្រិស្ដ។
- គ) ការរស់នៅ ទៅតាមបទពិសោធន៍ជាគ្រិស្ដបរិស័ទជារៀងរាល់ថ្ងៃ។

៩ លក្ខណៈរបស់ក្រុមជំនុំ ក្នុងនាមជាការសម្ដែងបង្ហាញឲ្យឃើញនឹងភ្នែកនូវទំនាក់ទំនងរបស់អ្នកជឿជាមួយនឹងព្រះគ្រិស្ដ អាចកំណត់និយមន័យថា ជា

- ក) ចំណងខាងវិញ្ញាណមួយនៃសេចក្ដីស្រឡាញ់សម្រាប់ព្រះជាម្ចាស់។
- ខ) កន្លែងមួយដែលមនុស្សចូលរួមគ្នាជាក្រុមដោយផ្អែកទៅតាម ជីវប្រវត្តិសាស្ត្រនៅក្នុងសង្គមផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីធ្វើការថ្វាយបង្គំព្រះ។
- គ) ការជំនុំគ្នារបស់ពួកអ្នកជឿនៅតាមតំបន់ ក្រោមទំនាក់ទំនងមួយនៃសហភាពជាមួយគ្នាទៅវិញទៅមក ដោយផ្អែកលើសេចក្ដីស្រឡាញ់។

ដូច្នេះ យើងឃើញថា តាមរយៈលក្ខណៈធម្មជាតិ ក្រុមជំនុំជារឿងខាងឯវិញ្ញាណ។ ទោះជាយ៉ាងណា ក្រុមជំនុំក៏ជាសហគមន៍ជាក់ស្តែងពិតមួយ ដែលអ្នកជឿសម្តែងទំនាក់ទំនងរបស់ពួកគេទៅកាន់ព្រះអម្ចាស់របស់ពួកគេ និង ចំពោះគ្នាទៅវិញទៅមក។ ដូច្នេះ ក្រុមជំនុំគឺជាសហគមន៍មួយរបស់អ្នកជឿដែលយើងឃើញ និង ទទួលបាននូវបទពិសោធន៍នៃក្តីស្រឡាញ់ដ៏ពិត។ ដោយសេចក្តីស្រឡាញ់ គឺជាលក្ខណសម្បត្តិចម្បងបំផុត នៃទំនាក់ទំនងខាងឯវិញ្ញាណ ហើយក្តីស្រឡាញ់មួយនេះ ត្រូវបានស្តែងឡើងនៅក្នុងការជំនុំគ្នាតាមតំបន់នេះហើយៈ

> រីឯអ្នកដែលមិនចេះស្រឡាញ់ មិនបានស្គាល់ព្រះជាម្ចាស់ទេ ដ្បិតព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់។ ព្រះជាម្ចាស់បានសំដែងព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គក្នុងចំណោមយើង គឺព្រះអង្គបានចាត់ព្រះបុត្រា តែមួយគត់របស់ព្រះអង្គអោយយាងមកក្នុងលោកនេះ ដើម្បីអោយយើងមានជីវិតដោយសារព្រះបុត្រា។ សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់មានដូចតទៅនេះ មិនមែនយើងទេដែលបានស្រឡាញ់ព្រះអង្គ គឺព្រះអង្គទេតើដែលបានស្រឡាញ់យើង និងបានចាត់ព្រះបុត្រារបស់ព្រះអង្គអោយយាងមកបូជាព្រះជន្ម លោះយើងអោយរួចពីបាបផង។កូនចៅជាទីស្រឡាញ់អើយ ប្រសិនបើព្រះជាម្ចាស់បានស្រឡាញ់យើងដល់កំរិតនេះទៅហើយ យើងក៏ត្រូវស្រឡាញ់គ្នាទៅវិញទៅមកដែរ។ (គម្ពីរ១យ៉ូហាន ៤:៨-១១)

## *លំហាត់អនុវត្តន៍*

១០ ដោយផ្អែកទៅលើព័ត៌មានមាននៅក្នុងទិដ្ឋភាពខាងលើនេះ ចូរប្រាប់លក្ខណសម្បត្តិពីរយ៉ាង ដែលរៀបរាប់អំពីលក្ខណៈរបស់ក្រុមជំនុំ។

..........................................................................................................................

..........................................................................................................................

# គ. អ្វីដែលក្រុមជំនុំធ្វើ

តើក្រុមជំនុំធ្វើអ្វីខ្លះ? តើអ្វីគឺជាគោលបំណងនៃវត្តមានរបស់ក្រុមជំនុំ? នៅក្នុងសំបុត្ររបស់លោកប៉ុល ទៅកាន់អ្នកជឿក្រុងអេភេសូ យើងដឹងថាព្រះជាម្ចាស់បង្កើតឲ្យសហគមន៍អ្នកជឿកើតចេញជារូបរាងមក ដើម្បីនាំសិរីរុងរឿងដល់ព្រះនាមរបស់ទ្រង់។ គោលបំណងធំបំផុតរបស់ទ្រង់ នៅក្នុងការប្រោសលោះយើង គឺដើម្បីឲ្យយើងអាច "លើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ" (គម្ពីរអេភេសូ ១:៦,១២,១៤)។

របៀបដែលក្រុមជំនុំតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់ គឺចែកចេញជាបីទិសដៅៈ

១. *ទៅខាងលើ* នៅពេលដែលអ្នកជឿថ្វាយបង្គំទ្រង់
២. *ទៅខាងក្នុង* នៅពេលដែលអ្នកជឿកសាងគ្នាឡើងទៅវិញទៅមក
៣. *ទៅខាងក្រៅ* នៅពេលដែលអ្នកជឿចែកចាយដំណឹងល្អ ជាមួយនឹងអ្នកមិនជឿ។

# ក្រុមជំនុំថ្វាយបង្គំព្រះជាម្ចាស់

**វត្ថុបំណងទី៤.** *ពិភាក្សាអំពីការចូលរួមថ្វាយបង្គំ និង បកស្រាយពីអ្វីដែលយើងថ្វាយទៅកាន់ព្រះជាម្ចាស់ក្នុងពេលថ្វាយបង្គំទ្រង់។*

ការថ្វាយបង្គំគឺជា សកម្មភាពមួយដែលយើងទទួលស្គាល់ភាពស័ក្តិសមរបស់ព្រះជាម្ចាស់ ក្នុងការទទួលបានការគោរពយ៉ាងជ្រាលជ្រៅ និង ការលើកតម្កើង។ នៅក្នុងការថ្វាយបង្គំរួមគ្នា អ្នកជឿលើកតម្កើង និង សម្តែងការគោរព ដោយផ្ទាល់ទៅចំពោះព្រះជាម្ចាស់ សម្រាប់ព្រះអំណោយទាន ប្រកបដោយព្រះគុណរបស់ទ្រង់ ទៅកាន់ប្រជារាស្ត្ររបស់ទ្រង់ នៅក្នុង និង តាមរយៈព្រះអម្ចាស់យេស៊ូវនៃយើង។ គោលបំណងនៃការថ្វាយបង្គំដ៏ពិតគឺមិនមែន មនុស្សទេ តែគឺជា*ព្រះជាម្ចាស់*វិញ ។ យើងថ្វាយបង្គំព្រះជាម្ចាស់ ដោយសារទ្រង់គឺជាទ្រង់ (លក្ខណសម្បត្តិរបស់ទ្រង់) និង អ្វីដែលទ្រង់ធ្វើ។

នៅក្នុងមេរៀនទី១ ដល់ទី៣ ក្នុងវគ្គសិក្សានេះ យើងបានមើលទៅលើមូលហេតុជាច្រើន ដែលព្រះជាម្ចាស់ទ្រង់ស័ក្តិសមទទួលការថ្វាយបង្គំរបស់យើង។ គម្ពីរទំនុកតម្កើង ១០៧:១-៣ ប្រាប់យើងថា "ចូរលើកតម្កើងព្រះអម្ចាស់ ដ្បិតព្រះអង្គមាន ព្រះហឫទ័យសប្បុរស ដ្បិតព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គនៅស្ថិតស្ថេររហូតតទៅ គួរអោយអស់អ្នកដែលព្រះអម្ចាស់ បានរំដោះមក ពោលសេចក្តីនេះ គឺអស់អ្នកដែលព្រះអង្គបានរំដោះ អោយរួចពីកណ្តាប់ដៃរបស់បច្ចាមិត្ត ហើយនាំពីប្រទេសនានាមកវិញ" ។

ព្រះយេស៊ូបានប្រកាសថា ព្រះជាម្ចាស់ស្វែងរកមនុស្សដែលនឹងថ្វាយបង្គំទ្រង់ "តាមវិញ្ញាណ និង តាមសេចក្តីពិត" (គម្ពីរយ៉ូហាន ៤:២៣)។ នេះបានន័យថា ការថ្វាយបង្គំរបស់យើងត្រូវតែប្រកបដោយភាពស្មោះត្រង់ និង ត្រូវផ្អែកលើទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងព្រះយេស៊ូគ្រិស្ត។ ការថ្វាយបង្គំគឺជាការដែលវិញ្ញាណរបស់យើង មានសម្ព័ន្ធភាពជាមួយព្រះវិញ្ញាណរបស់ទ្រង់។ តាមរយៈការប្រទានសេចក្តីសង្គ្រោះមក ព្រះជាម្ចាស់បានដកចេញជារៀងរហូត នូវរាល់រនាំងដែលអាចនឹងរារាំងការរួបរួមរបស់យើងទៅជាមួយព្រះជាម្ចាស់ (សូមមើលគម្ពីរហេព្រើ ៤:១៦; ១០:១៩-២២)។ ការថ្វាយបង្គំរបស់គ្រិស្តបរិស័ទដ៏ពិតគឺមិនផ្អែកទៅលើអ្វីដែលយើងធ្វើសម្រាប់ព្រះជាម្ចាស់នោះទេ ប៉ុន្តែគឺផ្អែកទៅលើការយល់ដឹងរបស់យើង និង ការទទួលស្គាល់អ្វីដែលទ្រង់បានធ្វើសម្រាប់យើងតាមរយៈការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូវិញ។

ការថ្វាយបង្គំរបស់យើងគឺមិនដូច អ្នកមិនជឿលើព្រះអម្ចាស់ ដែលនាំគ្នាទៅថ្វាយបង្គំព្រះដែលធ្វើពីឈើ ឬ ថ្មនោះទេ។ ការថ្វាយបង្គំរបស់ពួកគេ គឺមានគោលបំណងដើម្បីធ្វើឲ្យព្រះរបស់គេបាត់ខឹងនឹងពួកគេ ឬ ដើម្បីទទួលបានផលអ្វីម្យ៉ាងពីព្រះទាំងនោះប៉ុណ្ណោះ។ ទោះបីជា នៅពេលដែលប្រជារាស្ត្ររបស់ព្រះជាម្ចាស់ថ្វាយបង្គំទ្រង់ ពួកគេដឹងច្បាស់ថាទ្រង់បានប្រទានសេចក្តីមេត្តាករុណា និង ព្រះគុណសម្រាប់ពួកគេដោយឥតមានគិតថ្លៃអ្វីទាំងអស់ (គម្ពីរទំនុកតម្កើង ១១៨:១)។ ការថ្វាយបង្គំគឺជាការស្តែងចេញនូវការដឹងគុណទៅចំពោះព្រះជាម្ចាស់ សម្រាប់ព្រះគុណរបស់ទ្រង់។ ការនេះរាប់បញ្ចូលទាំងការសរសើរតម្កើង និង ការស្រឡាញ់ទ្រង់។

ស្របពេលដែលយើងអាច និង ធ្វើការថ្វាយបង្គំព្រះជាម្ចាស់ដូចខ្លួនឯង វាគឺជារឿងសំខាន់ណាស់ ដែលយើងត្រូវដឹងពីតម្លៃនៃការថ្វាយបង្គំរួមគ្នា ដែលជាការសរសើរតម្កើង *ព្រមគ្នា* មួយទៅកាន់ព្រះជាម្ចាស់។ នៅពេលដែលគ្រួសាររបស់ព្រះជាម្ចាស់ ប្រមូលផ្ដុំគ្នានៅក្នុងព្រះវត្តមានរបស់ទ្រង់ ដើម្បីតម្កើងសិរីរុងរឿងរបស់ទ្រង់ អ្នកជឿម្នាក់ៗអាចដឹងពីភាពរួមមកតែមួយនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ មាន*ភាពរស់រវើក* ខាងឯវិញ្ញាណមួយ នៅក្នុងការសហការគ្នាថ្វាយបង្គំ ដែលបុគ្គលតែម្នាក់មិនអាចទទួលបាន។ នេះមានន័យថា មានឫទ្ធានុភាពមួយកើតមានឡើងនៅពេលដែលយើងចូលរួមគ្នាដើម្បីថ្វាយបង្គំ ដែលឫទ្ធានុភាពនាំជាប្រយោជន៍ និង ពង្រឹងកម្លាំងអ្នកថ្វាយបង្គំម្នាក់ៗ។ យើងទទួលបានជំនួយនៅក្នុងការថ្វាយបង្គំព្រះជាម្ចាស់របស់ខ្ញុំ នៅពេលណាដែលខ្ញុំធ្វើការថ្វាយបង្គំទ្រង់ជាមួយអ្នកជឿដទៃទៀត។ ហេតុផលនោះហើយបានជា បទគម្ពីរបានជំរុញយើងថា៖ "តោងយើងមើលថែរក្សាគ្នាទៅវិញទៅមក ដើម្បីជួយដាស់តឿនគ្នាអោយមានចិត្តស្រឡាញ់ និងប្រព្រឹត្តអំពើល្អ។ មិនត្រូវលះបង់ការប្រជុំគ្នា ដូចអ្នកខ្លះធ្លាប់ធ្វើនោះឡើយ ផ្ទុយទៅវិញ យើងត្រូវលើកទឹកចិត្តគ្នាទៅវិញទៅមក" (គម្ពីរហេប្រឺ១០:២៤-២៥)។

ស្ថិតនៅក្នុងក្រោមការដឹកនាំ និង ការដោយផ្អែកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅក្នុងការថ្វាយបង្គំរួមគ្នា ក្រុមជំនុំព្យាយាមលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់តាមរយៈមធ្យោបាយផ្សេងដូចជាការច្រៀងបទចម្រៀង ការអធិស្ឋាន និងការធ្វើព័ន្ធកិច្ចតាមរយៈព្រះបន្ទូល។ ជារឿងសំខាន់ណាដែលយើងកត់ចំណាំថា ដោយគ្រាន់តែធ្វើតាមទម្រង់បែបបទនៃការថ្វាយបង្គំ មិនមែនមានន័យថា យើងបានថ្វាយបង្គំហើយនោះទេ។ យើងអាចរីករាយជាមួយ ភាពពិរោះរន្ធំនៃតន្ត្រី ជាមួយនឹងសមត្ថភាពរបស់អ្នកចែកចាយ ឬ បានសប្បាយដែលបាននៅជាមួយមនុស្សផ្សេងទៀត ហើយនៅតែមិនបានថ្វាយបង្គំព្រះជាម្ចាស់ដដែល។ ត្រូវចាំថា គោលបំណងចម្បងនៃការថ្វាយបង្គំព្រះជាម្ចាស់ដ៏ពិតគឺ ត្រូវតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។ ទ្រង់ត្រូវតែជាស្នូលកណ្ដាលនៃការថ្វាយបង្គំរបស់យើង។

ការថ្វាយបង្គំរួមគ្នា គឺ ត្រូវបង្ហាញឡើងជាច្រើនលើកច្រើនសា នៅក្នុងព្រះគម្ពីរ។ សូមឲ្យយើងក្រឡេកទៅមើល ឧទាហរណ៍ខ្លះៗអំពីការនេះ៖

> លោកអែសរ៉ាលើកតម្កើងព្រះអម្ចាស់ ជាព្រះដ៏ឧត្ដុង្គឧត្ដម ហើយប្រជាជនទាំងមូលឆ្លើយតបវិញទាំងលើកដៃឡើងលើថា «អាម៉ែន! អាម៉ែន!» រួចក្រាបថ្វាយបង្គំព្រះអម្ចាស់អោនមុខដល់ដី។ (គម្ពីរនេហេមា ៨:៦)។
>
> អង្គប្រជុំទាំងមូលនាំគ្នាក្រាបថ្វាយបង្គំ រីឯអ្នកចំរៀងនាំគ្នាច្រៀង ជាមួយសំឡេងត្រែ រហូតទាល់តែគេថ្វាយតង្វាយដុតចប់សព្វគ្រប់។ (គម្ពីរ ២របាក្សត្រ ២៩:២៨)។
>
> ជារៀងរាល់ថ្ងៃ គេរួមចិត្តគំនិតគ្នាព្យាយាមចូលព្រះវិហារ* ធ្វើពិធីកាច់នំប៉័ងនៅតាមផ្ទះ ព្រមទាំងបរិភោគអាហារជាមួយគ្នាយ៉ាងសប្បាយរីករាយ និងដោយចិត្តស្មោះសរផង។ គេនាំគ្នាសរសើរតម្កើងព្រះជាម្ចាស់ ហើយប្រជាជនទាំងមូលគោរពរាប់អានពួកគេទាំងអស់គ្នា។ ព្រះអម្ចាស់បន្ថែមចំនួនអ្នកដែលព្រះអង្គបានសង្គ្រោះ មកក្នុងក្រុមរបស់គេជារៀងរាល់ថ្ងៃ។
> (គម្ពីរ កិច្ចការ ២:៤៦-៤៧)។

ពេលនោះ ខ្ញុំឮសត្វលោកទាំងប៉ុន្មាន នៅស្ថានសួគ៌ នៅលើផែនដី នៅក្រោមដី នៅក្នុងសមុទ្រ ព្រមទាំងអ្វីៗទាំងអស់ដែលនៅស្ថានទាំងនោះ បន្លឺសំឡេងឡើងថាៈ «សូមព្រះអង្គដែលគង់លើបល្ល័ង្ក និងកូនចៀមទទួលពាក្យសរសើរតម្កើងព្រះកិត្តិនាម សិរីរុងរឿង និងព្រះចេស្ដា អស់កល្បជាអង្វែងតរៀងទៅ!»។ (គម្ពីរវិវរណៈ ៥:១៣)

បន្ថែមពីលើការច្រៀងចម្រៀង ការអធិស្ឋាន និង សរសើរតម្កើងព្រះជាម្ចាស់ ក្រុមជំនុំក៏ត្រូវថ្វាយបង្គំរួមគ្នាដោយការប្រតិបត្តិតាម បទបញ្ញាចំនួនពីរយ៉ាងដែលព្រះយេស៊ូបានបញ្ញាមក៖ ការជ្រមុជដោយទឹក និង ពិធីលៀងព្រះអម្ចាស់ ។ នៅក្នុងការជ្រមុជដោយទឹក អ្នកជឿថ្មី គឺត្រូវជ្រមុជនៅក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណដ៏វិសុទ្ធ ទុកជាទីសំគាល់មួយនៃការផ្លាស់ប្រែនៅផ្នែកខាងក្នុង។ ពិធីលៀងព្រះអម្ចាស់ ត្រូវតែប្រតិបត្តិតាមដែរ ព្រះយេស៊ូបានមានព្រះបន្ទូលថា ៖ "ដើម្បីរំលឹកដល់ខ្ញុំ រៀងរាល់ពេលដែលបងប្អូនពិសានំប៉័ង និងពិសាពីពែងនេះ បងប្អូនប្រកាសអំពីព្រះអម្ចាស់សោយទិវង្គត រហូតដល់ព្រះអង្គយាងមកវិញ។" ការស្ដាប់បង្គាប់តាមរយៈការប្រតិបត្តិតាមបទបញ្ញាទាំងនេះ គឺជាសកម្មភាពនៃការថ្វាយបង្គំរួមគ្នាមួយ (សូមមើល គម្ពីរម៉ាថាយ ២៨:១៩ គម្ពីរ១កូរិនថូស ១១:២២-២៦)។

## *លំហាត់អនុវត្តន៍*

១១ តើប្រយោគណាខ្លះ ក្នុងចំណោមប្រយោគខាងក្រោមនេះ ជាប្រយោគត្រឹមត្រូវទាក់ទងនឹងការថ្វាយបង្គំរួមគ្នា? ចូរគូសរង្វង់ជុំវិញអក្សរនៅខាងមុខចម្លើយដែលអ្នកបានជ្រើសរើស។

ក) គោលបំណងនៃការថ្វាយបង្គំរួមគ្នា គឺដើម្បីរម្ងាប់ព្រះពិរោធរបស់ព្រះជាម្ចាស់ និង ទទួលបានក្តីសន្ដោសរបស់ព្រះជាម្ចាស់។

ខ) ការថ្វាយបង្គំនៅក្នុងព្រះវិញ្ញាណ និង សេចក្ដីពិត គឺទាមទារឲ្យមានភាពស្មោះសរ និង ទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះយេស៊ូគ្រិស្ត។

គ) ការថ្វាយបង្គំរួមគ្នា ទាញអ្នកជឿឲ្យចូលមករកគ្នា នៅក្នុងការរួបរួម និង ឫទ្ធានុភាពតែមួយ។

ឃ) ការថ្វាយបង្គំដោយវិញ្ញាណគឺតែងតែផ្តោតទៅលើព្រះជាម្ចាស់។

ង) ការថ្វាយបង្គំរួមគ្នា គឺត្រូវបានបង្ហាញ និង បង្គាប់នៅក្នុងបទគម្ពីរ

១២ ចូរសរសេរពាក្យចំនួនបីពាក្យ ដែលបកស្រាយអំពីអ្វីដែលយើងថ្វាយទៅកាន់ព្រះជាម្ចាស់នៅក្នុងការថ្វាយបង្គំ។

..........................................................................................................................

# ក្រុមជំនុំកសាងឡើងដោយខ្លួនឯង

**វត្ថុបំណងទី៥.** *បកស្រាយពីអត្ថន័យនៃពាក្យ កសាងឡើង និង ទំនាក់ទំនងរវាងព្រះអំណោយទាន និង ផលផ្លែនៃព្រះវិញ្ញាណ និង ក្រុមជំនុំ។*

ការពិតមួយដែលបានបង្ហាញឲ្យយើងឃើញយ៉ាងច្បាស់ នៅពេលដែលយើងសិក្សាបទគម្ពីរទាក់ទងទៅនឹងតួនាទីរបស់ក្រុមជំនុំគឺថាៈ ព្រះជាម្ចាស់នៅតែបន្តដោះស្រាយជាមួយអ្នកជឿនៅក្នុង *សហគមន៍*។ យើងយល់អំពីតួនាទីរបស់សហគមន៍នេះ បានយ៉ាងល្អប្រសើរ នៅពេលដែលយើងទាក់ទងជាមួយនឹងក្រុមជំនុំដោយប្រកាន់គោលគំនិតនៃរូបកាយ។ បទគម្ពីរ ប្រើប្រាស់រូបភាពនៃរូបកាយនេះ ដើម្បីបកស្រាយអំពីតួនាទីរបស់ក្រុមជំនុំ រូបកាយនោះគឺជារូបកាយខាងឯវិញ្ញាណ (សូមមើលគម្ពីររ៉ូម ១២:៤-៨ គម្ពីរ១កូរិនថូស១២:៤-៣១ និង គម្ពីរអេភេសូ ៤:៧-១៦)។ សមាជិកគ្រប់រូប និង ការចូលរួមរបស់ពួកគេគឺមានសារៈសំខាន់ណាស់ សម្រាប់ដំណើរការដែលប្រកបដោយសុខភាព សម្រាប់រូបកាយ។

រូបកាយរបស់មនុស្ស គឺជាភាវៈរស់ដ៏ស្មុគស្មាញខ្លាំងណាស់ ។ រូបកាយរបស់មនុស្សមានទិដ្ឋភាពជាច្រើន ដែលនីមួយៗមានតួនាទីខុសៗពីគ្នា។ ព្រះកាយរបស់ព្រះគ្រិស្ត ទៀតសោតក៏មានសរីរាង្គ(អវយវៈពគប)ជាច្រើនផងដែរ។ សរីរាង្គទាំងអស់មានព្រះអំណោយទាន ឬ សមត្ថភាពមួយ ឬ ច្រើន ដែលអាចអនុញ្ញាតឲ្យពួកគេចូលរួម នៅក្នុងសុខុមលភាពរបស់ព្រះកាយទាំងមូល។ តើព្រះអំណោយទានទាំងនោះគឺមានអ្វីខ្លះ? ការរៀបរាប់ជាចំណុចៗ នឹងបង្ហាញឲ្យឃើញពីភាពដោយឡែកគ្នានៃព្រះអំណោយទានដែលមានសម្រាប់សរីរាង្គនៃព្រះកាយរបស់ព្រះគ្រិស្ត។

១. គម្ពីររ៉ូម ១២:៤-៨ : ការថ្លែងព្រះបន្ទូល ការបម្រើ ការបង្រៀន ការលើកទឹកចិត្ត រួមចំណែកនៅក្នុងតម្រូវការរបស់អ្នកដទៃ ការដឹកនាំ និង ការចែកទាន។

២. គម្ពីរ១កូរិនថូស ១២:៨-១០: ការនិយាយប្រកបដោយប្រាជ្ញា ការនិយាយដោយយល់គំពាង ការលាក់កំបាំង ជំនឿ ព្រះអំណោយទានប្រោសមនុស្សឲ្យជាពីជំងឺ ឫទ្ធានុភាពធ្វើការអស្ចារ្យ ការថ្លែងព្រះបន្ទូល ចេះស្ទង់មើលវិញ្ញាណល្អឬ អាក្រក់ សមត្ថភាពនិយាយភាសាចម្លែកអស្ចារ្យ និង ការបកស្រាយភាសានោះ (សូមមើលនៅក្នុង ខ២៨ - ខ៣០)

វាគឺជារឿងសំខាន់ ដែលត្រូវបញ្ជាក់ថា បុគ្គលដែលមានព្រះអំណោយទាន ត្រូវបានផ្តល់ទៅឲ្យ *ក្រុមជំនុំ សហគមន៍*នៃអ្នកជឿ "ដើម្បីរៀបចំប្រជាជនដ៏វិសុទ្ធអោយបំពេញមុខងារបំរើ និងកសាងព្រះកាយរបស់ព្រះគ្រិស្តឡើង" (គម្ពីរអេភេសូ ៤:១២)។ នេះមានន័យថា អ្នកជឿរស់នៅក្នុងទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ដោយផ្អែកលើគ្នាទៅវិញទៅមក។ សរីរាង្គនីមួយៗនៅក្នុងព្រះកាយរបស់ព្រះគ្រិស្តគឺសុទ្ធតែមានការបម្រើ ទេពកោសល្យ ឬ ត្រូវបានមានការចូលរួមខ្លះៗ សរីរាង្គនីមួយៗគឺសុទ្ធតែត្រូវការការចូលរួមពីសំណាក់សរីរាង្គដទៃផ្សេងទៀត។ សម្រាប់សរីរាង្គជារួមនៅក្នុងព្រះកាយវិញ ព្រះជាម្ចាស់បានប្រទានឲ្យមានពួកសាវ័ក អ្នកផ្សព្វផ្សាយដំណឹងល្អ គ្រូគង្វាល និង គ្រូបង្រៀន (គម្ពីរអេភេសូ ៤:១១)។

វាក៏ជារឿងសំខាន់ដែលយើងត្រូវ ចាំថា ព្រះកាយរបស់ព្រះគ្រិស្ត គឺជាភាវរស់ខាងឯវិញ្ញាណ ដែលរួបរួមជាមួយព្រះគ្រិស្ត។ នេះមានន័យថា ព្រះកាយគឺមិនមែនគ្រាន់តែជាបណ្តុំមនុស្សនោះទេ។ អស់អ្នកដែលជឿលើព្រះគ្រិស្ត គឺបានចូលរួមជាមួយព្រះកាយរបស់ទ្រង់ ព្រោះពួកគេក៏បានចូលរួមជាមួយនឹងព្រះ

សិរសាផងដែរ។ *ដោយសារតែសរីរាង្គទាំងអស់ គឺនៅជាមួយព្រះគ្រិស្ត នោះពួកគេក៏នៅជាមួយគ្នាទៅវិញទៅមកដែរ។* ព្រះកាយរស់នៅគឺដើម្បីបម្រើដល់ ព្រះសិរិសា។ នៅក្នុងរូបកាយរបស់មនុស្ស នៅពេលណាដែលខួរក្បាលស្លាប់ នោះក៏លែងត្រូវការខ្លួនប្រាណទៀតដែរ។ ប្រសិនបើព្រះគ្រិស្តមិនទទួលបានឋានៈរបស់ទ្រង់ជាព្រះសិរសាទេ នោះក៏លែងត្រូវការឲ្យមានព្រះកាយទៀតដែរ។ ព្រះយេស៊ូបានមានព្រះបន្ទូលទៅកាន់ក្រុមជំនុំនៅក្រុងសើដេសថា៖ "យើងស្គាល់កិច្ចការដែលអ្នកប្រព្រឹត្តនោះហើយ អ្នកមានឈ្មោះល្បីថារស់ តែតាមពិត អ្នកស្លាប់ទេតើ!" (គម្ពីរវិវរណៈ ៣:១)។ ក្រុមជំនុំត្រូវបានរក្សាទំនាក់ទំនងរបស់ពួកគេជាមួយព្រះសិរសា គឺព្រះយេស៊ូគ្រិស្ត តាមរយៈការថ្វាយបង្គំ ដើម្បីឲ្យក្រុមជំនុំអាចកសាងឡើងខ្លួនឯងបាន។ ការ*កសាងឡើង* មានន័យថា "ណែនាំ ឬ ធ្វើឲ្យវិញ្ញាណបានកាន់តែប្រសើរឡើង ជាការសាងសង់ ឬ បង្កើត"។

ព្រះជាម្ចាស់បានប្រទានភាពចុះសម្រុងគ្នា នៅក្នុងភាវរស់ខាងឯវិញ្ញាណ ដែលជាក្រុមជំនុំនេះ ។ នៅពេលដែលទិដ្ឋភាពខ្លះនៃខ្លួនប្រាណរបស់មនុស្ស ឆ្លើយតបទៅនឹងតម្រូវការនៃទិដ្ឋភាពនីមួយៗ នោះខ្លួនប្រាណខាងឯវិញ្ញាណ ក៏ឆ្លើយតបទៅនឹងតម្រូវការរបស់បុគ្គលអ្នកជឿម្នាក់ផងដែរ។ប្រសិនបើសរីរាង្គណាមួយរងទុក្ខ នោះសរីរាង្គផ្សេងទៀតនឹងទទួលរងការឈឺចាប់ដូចគ្នា ប្រសិនបើមានសរីរាង្គណាមួយត្រេកអរសប្បាយ សរីរាង្គដទៃក៏នឹងទទួលបានអំណរសប្បាយដូចគ្នានោះដែរ (គម្ពីរ១កូរិនថូស ១២:២៤-២៦)។ ហេតុផលគឺយ៉ាងដូច្នេះ ៖ "ព្រះកាយទាំងមូលបានផ្គុំគ្នា និងភ្ជាប់គ្នាឡើងយ៉ាងមាំ ដោយសារសន្លាក់ឆ្អឹងទាំងប៉ុន្មានដែលបំរើព្រះកាយ តាមកំរិតសមត្ថភាពរបស់សរីរាង្គនីមួយៗ ដើម្បីអោយព្រះកាយនោះចំរើន និងកសាងឡើង ក្នុងសេចក្ដីស្រឡាញ់។" (គម្ពីរអេភេសូ ៤:១៦)។

ពេលខ្លះ ដំណើរការនៃការសាងសង់រូបកាយឡើង មានន័យថាក្រុមជំនុំត្រូវបន្សុទ្ធខ្លួនឯង។ ការនេះអាចនឹងត្រូវទាមទារឲ្យមានការអប់រំសមាជិកណាដែលបានប្រព្រឹត្តិអំពើបាប។ ព្រះយេស៊ូបានមានព្រះបន្ទូលអំពី ការនេះ (គម្ពីរម៉ាថាយ ១៨:១៥-២០) ហើយបានប្រទានការណែនាំសម្រាប់ដោះស្រាយជាមួយនឹងមនុស្សប្រភេទតាមរយៈវិញ្ញាណនៃក្ដីស្រឡាញ់។ ទោះជាយ៉ាងណា ប្រសិនបើពួកគេបដិសេធមិនព្រមស្ដាប់ ហើយលន់តួនោះទេ ពួកអ្នកទាំងនោះ ត្រូវតែបណ្ដេញចេញពីសមាគមន៍នៃអ្នកជឿតែម្ដង(សូមមើលផងដែរនៅក្នុងគម្ពីរ១កូរិនថូស ៥:៩-១៣ ដើម្បីធ្វើជាឧទាហរណ៍)។

មានតែតាមរយៈទំនាក់ទំនងរបស់អ្នកជឿជាមួយសមាជិកដទៃទៀតនៃព្រះកាយរបស់ព្រះគ្រិស្តនោះទេ ដែលព្រះវិញ្ញាណអាចបង្កើតផលផ្លែរបស់ទ្រង់បាន នៅក្នុងអ្នកជឿម្នាក់ៗ។ ផលផ្លែនៃព្រះវិញ្ញាណដូចដែលបានរៀបរាប់នៅក្នុងគម្ពីរកាឡាទី ៥:២២-២៣ គឺសំដៅទៅលើលក្ខណសម្បត្តិរបស់ព្រះគ្រិស្តដែលកើតមានឡើងនៅពេលដែលយើងបង្កើតទំនាក់ទំនងជាមួយជាគ្នាទៅវិញទៅមក។ ផលផ្លែទាំងនោះមាន សេចក្ដីស្រឡាញ់ អំណរ សេចក្ដីសុខសាន្ត ចិត្តអត់ធ្មត់ ចិត្តសប្បុរស ចិត្តសន្ដោសមេត្តា ជំនឿ (ភាពស្មោះត្រង់, គកស១៦) ចិត្តស្លូតបូត និង ចេះទប់ចិត្តខ្លួនឯង។

## *លំហាត់អនុវត្តន៍*

១៣ ចូរបំពេញប្រយោគខាងក្រោម ៖

ក) ក្រុមជំនុំកសាងឡើងដោយខ្លួនឯង។ *ការកសាង* មានន័យថា........................................

ខ) ទំនាក់ទំនងរវាងព្រះអំណោយទាននៃព្រះវិញ្ញាណ និង ក្រុមជំនុំគឺថា...............................

..........................................................................................................

គ) ទំនាក់ទំនងរវាងផលផ្លែនៃព្រះវិញ្ញាណ និង ក្រុមជំនុំគឺថា.............................................

..........................................................................................................

គ្រិស្ដបរិស័ទ គឺមិនមែនជាដំណើរឯកោ ឬ តែម្នាក់ឯងនោះទេ។ តាមរយៈការអានគម្ពីរកិច្ចការ បានបង្ហាញឲ្យឃើញថា ព្រះកាយរបស់ព្រះគ្រិស្ដគឺ អ្នកជឿដែលប្រមូលផ្ដុំគ្នាយ៉ាងមមាញឹក ធ្វើការថ្វាយបង្គំ និង ប្រកបគ្នា ក្នុងគោលបំណងដើម្បីតម្កើងសិរីរុងរឿងព្រះជាម្ចាស់ រីកលូតលាស់នៅក្នុងក្ដីស្រឡាញ់របស់ទ្រង់ និង នាំអ្នកដទៃទៀតចូលមកឯព្រះរាជ្យរបស់ទ្រង់។ ក្រុមជំនុំ គឺសម្រាប់អស់អ្នកដែលបានប្ដេជ្ញាចិត្តចំពោះការលូតលាស់ ការអភិវឌ្ឍ និង ការពេញវ័យរបស់សរីរាងនៃព្រះកាយរបស់ព្រះគ្រិស្ដ។ នៅពេលការនេះកើតឡើង ក្រុមជំនុំនឹងត្រៀមខ្លួនជាស្រេចក្នុងការបំពេញមុខងារទីបីរបស់ខ្លួន នោះគឺការចែកចាយដំណឹងល្អជាមួយអ្នកមិនជឿ។

# ក្រុមជំនុំផ្សព្វផ្សាយទៅកាន់ពិភពលោក

**វត្ថុបំណងទី ៦.** *បកស្រាយពីរបៀបដែលសេចក្ដីបង្រៀនរបស់ព្រះយេស៊ូ ទាក់ទងនឹងបេសកកម្មរបស់ក្រុមជំនុំ គួរតែត្រូវបានយកទៅដាក់ឲ្យប្រតិបត្តិ។*

ព្រះរាជបញ្ជាទីមួយរបស់ព្រះយេស៊ូ ទៅកាន់អ្នកដែលមានតម្រូវការគឺ "ចូរមក" (គម្ពីរម៉ាថាយ ១១: ២៨)។ នៅពេលដែលគេស្គាល់ ការអត់ទោស និង ការទទួលស្គាល់របស់ទ្រង់ហើយ ពួកគេត្រូវបានចាត់ឲ្យ "ចេញទៅ" (គម្ពីរម៉ាថាយ២៨:១៩)។ នៅពេលសមាគមន៍នៃអ្នកជឿដែលបានចូលរួមនៅក្នុងតំបន់នីមួយៗ ត្រូវបានកសាងឡើងខាងឯជំនឿរបស់គេហើយ គេត្រូវតែបង្វែរកម្លាំងរបស់គេ ទៅខាងក្រៅ គឺទៅកាន់លោកីយ៍ដែលមិនជឿ។ ព្រះជាម្ចាស់ប្រើប្រាស់មនុស្សដើម្បី ឈោងចាប់មនុស្ស! ក្រុមជំនុំ តម្កើងសិរីរុងរឿងព្រះជាម្ចាស់ នៅពេលដែលអ្នកជឿចែកចាយដំណឹងល្អជាមួយអ្នកដទៃទៀត ពួកគេគឺចូលរួមនៅក្នុងការផ្សាយដំណឹងល្អ។ ពាក្យ*ផ្សព្វផ្សាយដំណឹងល្អ*មានន័យត្រង់ៗថា៖ "ការប្រកាសដំណឹងល្អ"។ ទំនួលខុសត្រូវ និង អភ័យឯកសិទ្ធិ របស់ក្រុមជំនុំគឺត្រូវធ្វើឲ្យការប្រទានសេចក្ដីសង្គ្រោះរបស់ព្រះជាម្ចាស់ទៅកាន់មនុស្សគ្រប់គ្នា ត្រូវបានគេដឹងឮ។

អ្នកជឿត្រូវបានត្រាស់ហៅឲ្យចេញទៅក្នុងលោកីយ៍ ក្នុងន័យមួយដែលថា ពួកគេមិនត្រូវបានគ្រប់គ្រងដោយតម្លៃ និង ភក្ដីភាពរបស់លោកីយ៍ទៀតទេ។ យ៉ាងណាក៏ដោយ ពួកគេក៏ត្រូវបានចាត់ឲ្យនាំយកដំណឹងល្អទៅកាន់ពិភពរបស់អ្នកដែលមិនមែនជាគ្រិស្ដបរិស័ទ ។ ព្រះយេស៊ូបានអធិស្ឋាន ទៅកាន់ព្រះវរបិតាថា៖ " គេមិនកើតពីនិស្ស័យលោកីយ៍ទេ ដូចទូលបង្គំមិនកើតពីនិស្ស័យលោកីយ៍នេះ

ដែរ។... ទូលបង្គំចាត់គេអោយទៅក្នុងលោក ដូចព្រះអង្គបានចាត់ទូលបង្គំអោយមកក្នុងលោកដែរ។" (គម្ពីរយ៉ូហាន ១៧:១៦,១៨) ។ អ្នកជឿត្រូវផ្តាច់ខ្លួនរបស់ពួកគេចេញពី របៀបរស់នៅបែបអ្នកដែលមិនមែនជាគ្រិស្តបរិស័ទ ហើយនៅតែបន្តចូលរួមនៅក្នុងការផ្លាស់ប្តូររបៀបរស់នៅនោះដដែល។ ដោយសារតែគ្រិស្តបរិស័ទត្រូវបាន *ចាត់បញ្ជូនទៅ* ពួកយើងមានគំនិតអំពី *បេសកកម្ម* ។

ព្រះគម្ពីរសម្ព័ន្ធមេត្រីថ្មី ផ្តល់ឲ្យយើងឃើញពីវិសាលភាពនៃការផ្សព្វផ្សាយដំណឹងល្អ នៅក្នុងគម្ពីរម៉ាថាយ ១៣:៣៨។ ព្រះយេស៊ូប្រកាសថា៖ "ស្រែ គឺពិភពលោក" ។ ទ្រង់បានបង្គាប់អ្នកដើរតាមទ្រង់ជាមួយនឹងព្រះបន្ទូលយ៉ាងដូច្នេះថា៖ "ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍អោយធ្វើជាសិស្ស ហើយធ្វើពិធីជ្រមុជទឹកអោយគេ .... ត្រូវបង្រៀនគេអោយប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។" (គម្ពីរម៉ាថាយ ២៨:១៩-២០ ហើយក៏សូមមើលនៅក្នុងគម្ពីរម៉ាកុស ១៦:១៥)។ ដូច្នេះ ក្រុមជំនុំត្រូវបានដាក់តួនាទីឲ្យចែកចាយដំណឹងល្អ ជាមួយមនុស្សនៅគ្រប់ទីកន្លែង។

ទំនួលខុសត្រូវ ដើម្បីផ្សព្វផ្សាយដំណឹងល្អ គឺមិនមែនជាបញ្ហា រឿងជម្រើស សម្រាប់គ្រិស្តបរិស័ទនោះទេ។ ព្រះយេស៊ូបានមានព្រះបន្ទូលថា នៅពេលដែលអ្នកជឿទទួលបានឫទ្ធានុភាពរបស់ព្រះវិញ្ញាណដ៏វិសុទ្ធហើយ ពួកគេមុខជាក្លាយជាសក្ខីភាពដ៏រស់រវើក "នៅក្នុងក្រុងយេរូសាឡឹម ក្នុងស្រុកយូដាទាំងមូល ក្នុងស្រុកសាម៉ារី និងរហូតដល់ស្រុកដាច់ស្រយាលនៃផែនដី" (គម្ពីរកិច្ចការ ១:៨)។ ព្រះជាម្ចាស់ទទួលបានការតម្កើងសិរីរុងរឿង នៅពេលមនុស្សបម្រើ និង ចូលមកបន្ថែមនៅក្នុងព្រះកាយរបស់ព្រះគ្រិស្ត ដ្បិតនៅក្នុងដំណើរការនេះ គ្រិស្តបរិស័ទ គឺបានក្លាយជាអ្នកជឿដែលមានប្រយោជន៍ និង មានផលផ្លែ ដែលព្រះគ្រិស្តបម្រុងសម្រាប់ពួកគេ (គម្ពីរយ៉ូហាន ១៥:១-៨)។

## *លំហាត់អនុវត្តន៍*

១៤ កណ្ឌគម្ពីរកិច្ចការ ផ្តល់ឲ្យយើងនូវចំណេះដឹងខ្លះ អំពីរបៀបដែលយើងគួរមើលទៅកាន់ទំនួលខុសត្រូវរបស់យើង ក្នុងការចែកចាយដំណឹងល្អ។ ចូរអានខគម្ពីរទាំងនេះ ហើយប្រាប់ថា តើពួកសាវ័កបានឆ្លើយតបយ៉ាងដូចម្តេចនៅក្នុងព្រឹត្តិការណ៍នីមួយៗ៖

ក) គម្ពីរកិច្ចការ ៤:១៦-២០

ខ) គម្ពីរកិច្ចការ ៤:៣១

គ) គម្ពីរកិច្ចការ ៥:៤០-៤២

មានមនុស្សជាច្រើនកោដិ(បច្ចុប្បន្ន២០២៥ ប្រហែល៨.២កោដិ)នាក់នៅលើផែនដីនេះ។ មានការប៉ាន់ប្រមាណ មួយថា ប្រហែលជាពីរភាគបីនៃមនុស្សទាំងអស់នេះ មិនបានទទួលបន្ទាល់អំពីដំណឹងល្អរបស់ព្រះយេស៊ូគ្រិស្តបានគ្រប់គ្រាន់នៅឡើយទេ។ ព្រះអម្ចាស់ដែលជាម្ចាស់ស្រែទ្រង់បាន ចាត់យើងឲ្យទៅប្រកាសដំណឹងល្អរបស់ទ្រង់ ទៅកាន់ពួកគេ។ ទ្រង់បានចាក់បង្ហូរព្រះវិញ្ញាណរបស់ទ្រង់មកលើពួកអ្នកបម្រើទ្រង់ ទូទាំងពិភពលោក ជំរុញពួកគេឲ្យថ្វាយខ្លួនរបស់ពួកគេដើម្បីធ្វើការងារផ្សព្វផ្សាយដំណឹងល្អដែលមិនទាន់បានចប់សព្វគ្រប់។ ទ្រង់មិនត្រឹមតែបានបំពាក់បំប៉ន់ក្រុមជំនុំ ជាមួយនឹងឫទ្ធានុភាពរបស់ព្រះវិញ្ញាណនោះទេ តែរួមជាមួយនឹងឧបករណ៍ដ៏មានប្រសិទ្ធិភាព ដើម្បីឲ្យក្រុមជំនុំអាចសម្រេចបាននូវ

បេសកកម្មរបស់ខ្លួន ដែលមានដូចជា វិទ្យុ ទូរទស្សន៍ សំណេរ និង ការប្រជុំផ្សព្វផ្សាយដំណឹងល្អធំៗ (នៅក្នុងវប្បធម៌របស់ប្រទេសខ្លះ)។ ដំណឹងល្អត្រូវបានប្រកាសជាលក្ខណៈទ្រង់ទ្រាយធំ ជាងពីមុន តាមរយៈមធ្យោបាយទាំងអស់នេះ។ ទោះជាយ៉ាងណា មធ្យោបាយដែលអស្ចារ្យជាងគេក្នុងការផ្សាយដំណឹងល្អ ទៅកាន់មនុស្សនៅក្នុងពិភពលោក គឺផ្អែកទៅលើសក្ខីភាពដ៏មានប្រសិទ្ធិភាព និង គំរូដូចជាព្រះគ្រិស្ត នៅក្នុងអ្នកជឿម្នាក់ៗ ទៅតាមកន្លែងរៀងៗខ្លួនរបស់គេ។

បន្ទាប់មកទៀត គោលដៅរបស់យើងគឺគួរតែត្រូវមើលឲ្យឃើញថា បុគ្គលម្នាក់ៗដែលបាននាំមកឯព្រះគ្រិស្ត និងបាននាំចេញពីលោកីយ៍ ត្រូវបានចាត់ឲ្យត្រឡប់ទៅក្នុងលោកីយ៍វិញ ក្នុងនាមជាទូតម្នាក់សម្រាប់ព្រះគ្រិស្ត។ ជាមួយនឹងជំនឿថ្មី និង ខ្នាតគំរូថ្មី អ្នកជឿម្នាក់ៗត្រូវបានព្រះជាម្ចាស់បម្រុងឲ្យចូលទៅឯលោកីយ៍ម្តងទៀត ក្នុងនាមជាអ្នកតំណាងរបស់ទ្រង់ ប្រទានសេចក្តីសង្គ្រោះទៅដល់មនុស្សគ្រប់គ្នា។ តាមរបៀបនេះហើយ ដែលក្រុមជំនុំអាចបំពេញបេសកកម្មរបស់ខ្លួន ដោយការស្តាប់បង្គាប់ និង មានប្រសិទ្ធិភាព និង នាំយកសិរីរុងរឿងមកថ្វាយព្រះម្ចាស់ក្នុងពេលជាមួយគ្នានោះដែរ។

## លំហាត់អនុវត្តន៍

១៥ ចូរឆ្លើយសំណួរខាងក្រោម យ៉ាងខ្លីៗ៖

ក) តើការបង្គាប់បញ្ជារបស់ព្រះគ្រិស្តទៅកាន់មនុស្សមានបាប គឺអ្វី? (ចូរប្រើពាក្យតែមួយ)

ខ) តើការបង្គាប់បញ្ជារបស់ព្រះគ្រិស្តទៅកាន់អ្នកជឿ គឺអ្វី? (ចូរប្រើពាក្យតែមួយ)

គ) តើអ្វីជារបស់សំខាន់ជាងគេ ដែលព្រះយេស៊ូបានប្រទានទៅកាន់ក្រុមជំនុំ សម្រាប់បំពេញបេសកកម្មរបស់ពួកគេ?

ឃ) តើអ្នកណាដែលត្រូវបានព្រះជាម្ចាស់ប្រើប្រាស់ដើម្បី ឈោងចាប់មនុស្សដែលបានបាត់បង់?

ង) ព្រះយេស៊ូបានមានព្រះបន្ទូលថាអ្នកជឿ មិនមែនកើតមកមាននិស្ស័យលោកីយ៍នោះទេ ។ តើទ្រង់មានចង់មានន័យយ៉ាងដូចម្តេច?

ច) តើទ្រង់ចង់មានន័យយ៉ាងដូចម្តេច នៅពេលដែលទ្រង់មានព្រះបន្ទូលថា អ្នកជឿគឺនៅក្នុងពិភពលោក?

ឆ) ឧទាហរណ៍មួយអំពីពួកសាវ័ក នៅក្នុងកណ្ឌគម្ពីរកិច្ចការ បង្រៀនយើងថា ទាក់ទងទៅនឹងបេសកកម្មរបស់ក្រុមជំនុំ តើពួកគេគួរមានឥរិយាបថយ៉ាងដូចម្តេច?

# *ការប្រឡងផ្ទាល់ខ្លួន*

**សំណួរពហុជម្រើស។** ចូរជ្រើសរើសចម្លើយមួយដែលល្អបំផុត សម្រាប់សំណួរនីមួយៗ។

១ ការប្រើប្រាស់ពាក្យថា *ក្រុមជំនុំ* នៅក្នុងព្រះគម្ពីរ គឺសំដៅទៅលើ

ក) ក្រុមមនុស្សដែលមានជំនឿស្រដៀងគ្នា។

ខ) សហគមន៍មនុស្សដែលឆ្លើយតបទៅនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់។

គ) កន្លែងដែលមនុស្សជួបជុំគ្នា ដើម្បីថ្វាយបង្គំ។

ឃ) ក្រុមមនុស្សដែលមានទស្សនៈគោលលទ្ធិដូចគ្នា។

២ ឧទាហរណ៍នៅក្នុងព្រះគម្ពីរអំពីក្រុមជំនុំ ដែលជាព្រះកាយដែលមានច្រើនទិដ្ឋភាព បញ្ជាក់ថា

ក) មនុស្សដែលបានមកជួបជុំគ្នានៅក្នុងនាមព្រះនាមរបស់ព្រះជាម្ចាស់ បង្កើតបានទៅជាក្រុមជំនុំមួយ។

ខ) មនុស្សម្នាក់ៗ នៅក្នុងទំនាក់ទំនងជាមួយព្រះគ្រិស្ត គឺជាក្រុមជំនុំរបស់ទ្រង់។

គ) ក្រុមជំនុំគឺមានរួមបញ្ចូលមនុស្សជាច្រើននាក់ នៅក្នុងទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ដោយសារតែទំនាក់ទំនងជាលក្ខណៈបុគ្គលរបស់ពួកគេម្នាក់ជាមួយព្រះគ្រិស្ត។

ឃ) ការជួបប្រជុំនីមួយៗគឺត្រូវបានរៀបចំឡើងតាមរបៀបដូចគ្នាទាំងអស់។

៣ ក្រុមជំនុំតាមតំបន់ ឬ ក្រុមជំនុំដែលអាចមើលឃើញ គឺសំដៅទៅលើ

ក) ព្រះកាយទាំងមូលរបស់ព្រះគ្រិស្ត។

ខ) អ្នកជឿដែលមកពីកន្លែងណាមួយ ដែលមានជំនឿដូចគ្នាទៅលើព្រះយេស៊ូគ្រិស្ត និង ជាអ្នកដែលបានជួបប្រជុំគ្នា ដើម្បីធ្វើការថ្វាយបង្គំ។

គ) អ្នកជឿទាំងអស់ មកពីនិកាយតែមួយ។

ឃ) ក្រុមជំនុំសាកល។

៤ ពាក្យថា *សហគមន៍* បានផ្តល់នូវគំនិតអំពី

ក) រាជរដ្ឋាភិបាល

ខ) ក្រុមជំនុំមួយដែលគេមិនអាចមើលឃើញ។

គ) មនុស្សដែលមានគំនិតខុសៗពីគ្នា ក្នុងការធ្វើអ្វីមួយ។

ឃ) ការចែករំលែក និង ការប្រកបរួមគ្នា។

៥ ព្រះគម្ពីរផ្តល់នូវភស្តុតាងថា ក្រុមជំនុំបានចាប់ផ្តើម

ក) ក្នុងអំឡុងពេលដែលព្រះយេស៊ូធ្វើព័ន្ធកិច្ចនៅលើផែនដី។

ខ) នៅក្នុងពេលដែលព្រះយេស៊ូយាងត្រឡប់ទៅឯនគរស្ថានសួគ៌វិញ។

គ) នៅថ្ងៃបុណ្យថ្ងៃទីហាសិប។

ឃ) បន្ទាប់ពីលោកប៉ូលប្រែចិត្តជឿ។

៦ និស្ស័យខាងវិញ្ញាណរបស់ក្រុមជំនុំ គឺត្រូវបានស្តែងឲ្យឃើញនៅក្នុង
ក) ការបង្ហាញពីការរួបរួមរបស់ពួកអ្នកជឿ និង សេចក្តីស្រឡាញ់សម្រាប់គ្នាទៅវិញទៅមក។
ខ) ការគង់នៅរបស់ព្រះគ្រិស្តនៅក្នុងដួងចិត្តរបស់អ្នកជឿ។
គ) ព្រះអំណោយទាននៃព្រះវិញ្ញាណ។
ឃ) ការច្រៀង ការអធិស្ឋាន និង ការចែកចាយព្រះបន្ទូល។

៧ តើអ្វីជាភស្តុតាងល្អបំផុត ដែលបង្ហាញថាមនុស្សស្រឡាញ់ព្រះជាម្ចាស់?
ក) ពួកគេស្រឡាញ់អ្នកដទៃ។
ខ) ពួកគេចំណាយពេលវេលាជាច្រើនម៉ោង ក្នុងការអធិស្ឋាន និង ការថ្វាយបង្គំ។
គ) ពួកគេក្លាយជាសមាជិកនៃក្រុមជំនុំតាមតំបន់។
ឃ) ពួកគេធ្វើសក្ខីភាពទៅកាន់អ្នកមិនជឿ។

៨ ព្រះគម្ពីរបង្រៀនថា ព្រះអំណោយទាននៃព្រះវិញ្ញាណគឺត្រូវបានផ្តល់ទៅឲ្យ
ក) បុគ្គលណាដែលចង់មានព័ន្ធកិច្ចផ្ទាល់ខ្លួន។
ខ) ក្រុមជំនុំសម្រាប់ការកសាងឡើង ការប្រតិបត្តិការតាមរយៈអ្នកជឿ នៅពេលដែលពួកគេបម្រើគ្នាទៅវិញទៅមក។
គ) ដើម្បីឲ្យក្រុមជំនុំផ្សព្វផ្សាយដំណឹងល្អទៅកាន់ពិភពលោក។
ឃ) ដើម្បីបង្កើតបានទៅជាលក្ខណៈដូចជាព្រះគ្រិស្ត នៅក្នុងអ្នកដែលមានអំណោយទាន។

៩ នៅក្នុងឧទាហរណ៍ ដែលប្រាប់ថាក្រុមជំនុំគឺជាព្រះកាយរបស់ព្រះគ្រិស្ត យើងដឹងថា ក្រុមជំនុំលក្ខណៈរបស់ក្រុមជំនុំគួរបានមកពី
ក) សមាជិក
ខ) កិច្ចការ
គ) ព្រះសិរសា
ឃ) ការជួបជុំ និង ការប្រកបគ្នា

១០ **ចម្លើយខ្លីៗ** ។ ចូរបកស្រាយថាក្រុមជំនុំ មានគោលបំណងអ្វីខ្លះទាក់ទងនឹងចំណុចនីមួយៗខាងក្រោមនេះ៖
ក) ទាក់ទងនឹងព្រះជាម្ចាស់៖.............................................................................
ខ) ទាក់ទងនឹងក្រុមជំនុំខ្លួនឯងផ្ទាល់៖...................................................................
គ) ទាក់ទងនឹងពិភពលោក៖................................................................................

# *ចម្លើយសម្រាប់លំហាត់អនុវត្តន៍*

៨ ខ) អ្នកជឿទាំងអស់ ដែលស្ថិតនៅក្នុងការរួបរួមមួយជាមួយព្រះគ្រិស្ត។

១ ចម្លើយរបស់អ្នក

៩ គ) ការជំនុំគ្នារបស់ពួកអ្នកជឿនៅតាមតំបន់ ក្រោមទំនាក់ទំនងមួយនៃសហភាពជាមួយគ្នាទៅវិញទៅមក ដោយផ្អែកលើសេចក្តីស្រឡាញ់។

២ ខ) ការជំនុំមនុស្សរបស់ព្រះជាម្ចាស់ ដែលជួបគ្នា និង ចែកចាយពីជំនឿដូចគ្នា និង ភាពស្មោះស្ម័គ្រដូចគ្នា ចំពោះព្រះយេស៊ូគ្រិស្ត។

គ) ការប្រកបគ្នាដែលត្រូវបានបង្កើតឡើងដោយព្រះជាម្ចាស់ នៃអ្នកជឿដែលជឿទុកចិត្តលើព្រះសង្គ្រោះដូចគ្នា និង ជាអ្នកដែលមានការរួបរួម ជាមួយគ្នាទៅវិញទៅមក ក៏ដោយសារតែការរួបរួមរបស់ពួកគេជាមួយនឹងទ្រង់។

ង) សហគមន៍នៅទូទាំងពិភពលោកទាំងមូល នៃអ្នកជឿដែលបានទទួលស្គាល់ជំនឿដូចគ្នាទៅលើព្រះជាម្ចាស់ និង ទទួលស្គាល់ភាពជាព្រះអម្ចាស់របស់ព្រះយេស៊ូគ្រិស្ត។

១០ វាគឺជាទំនាក់ទំនងនៃក្តីស្រឡាញ់រវាងអ្នកជឿ និង ព្រះគ្រិស្ត។ គឺជាទំនាក់ទំនងនៃក្តីស្រឡាញ់របស់អ្នកជឿសម្រាប់គ្នាទៅវិញទៅមក។

៣ ខ) បទគម្ពីរនេះផ្តល់នូវភស្តុតាងដែលបង្ហាញថា ការសុគត ការមានព្រះជន្មរស់ និង ការយាងត្រឡប់ទៅស្ថានសួគ៌របស់ទ្រង់កើតឡើងតាំងពីមុនពេលដែលទ្រង់អាចបង្កើតក្រុមជំនុំរបស់ទ្រង់មកម្ល៉េះ។

១១ ចម្លើយទាំងអស់សុទ្ធតែត្រឹមត្រូវ លើកលែង ចម្លើយក)

៤ ពួកសិស្សបានពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដូចដែលព្រះយេស៊ូបានមានព្រះបន្ទូលសន្យា។ មនុស្សប្រមាណ ៣០០០នាក់ បានទទួលយកសារដំណឹងល្អ និង បានបន្ថែមទៅលើចំនួនរបស់អ្នកជឿ។

១២ ចម្លើយមួយណាក៏បាន៖ សិរីរុងរឿង កិត្តិយស ការគោរព ការសរសើរ ការអរព្រះគុណ និង ការស្តាប់បង្គាប់។

៥ ប្រៀបធៀបចម្លើយរបស់អ្នកជាមួយការរៀបរាប់របស់យើង នៅក្នុងមេរៀននេះ បន្ទាប់មកប្រៀបធៀបជាមួយនឹងតួនាទីនៅក្នុងក្រុមជំនុំតាមតំបន់របស់អ្នក។

១៣ ចម្លើយរបស់អ្នកគួរតែស្រដៀងនឹងចម្លើយទាំងនេះ៖
ក)ការកសាងឡើង ការបង្កើត ការណែនាំ ការធ្វើឲ្យប្រសើរឡើង ការពង្រឹងកម្លាំង ឬ ការអប់រំ។
ខ) ព្រះអំណោយទានដែលប្រទានទៅឲ្យក្រុមជំនុំ ឬ សម្រាប់ប្រយោជន៍របស់ក្រុមជំនុំជារួម។ ព្រះអំណោយទានត្រូវបានស្តែងចេញឡើងនៅក្នុងការថ្វាយបង្គំរួមគ្នា។
គ) ព្រះវិញ្ញាណបង្កើតបានជាផលផ្លែរបស់ទ្រង់ នៅក្នុងយើងរាល់គ្នា តាមរយៈទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃ។ ផលផ្លែនៃព្រះវិញ្ញាណមិនអាចដុះបាន នៅក្រៅទំនាក់ទំនងនេះឡើយ។

៦ ក) ១) បុគ្គលអ្នកជឿម្នាក់ៗ
ខ) ២) ក្រុមជំនុំតាមតំបន់
គ) ២) ក្រុមជំនុំតាមតំបន់
ឃ) ៣) ក្រុមជំនុំសាកល
ង) ៣) ក្រុមជំនុំសាកល
ច) ១) បុគ្គលអ្នកជឿម្នាក់ៗ

១៤ ក) ពួកគេមិនអាចធ្វើអ្វីបានទេ ក្រៅតែពីការនិយាយអំពីអ្វីដែលគេបានឃើញ និង បានឮ។
ខ) ពួកគេបានថ្លែងព្រះបន្ទូលរបស់ព្រះជាម្ចាស់ យ៉ាងអង់អាចក្លាហាន។
គ) ពួកគេមិនបានឈប់ បង្រៀន និង ប្រកាសដំណឹងល្អដែលថាព្រះយេស៊ូគឺជាព្រះគ្រិស្តបានឡើយ។

៧ ក) ឃ) ង) ឆ) និង ជ) គឺជាចម្លើយត្រឹមត្រូវ។

១៥ ក) មក
ខ) ទៅ
គ) ព្រះវិញ្ញាណដ៏វិសុទ្ធ
ឃ) អ្នកជឿ (ក្រុមជំនុំ)
ង) អ្នកជឿបានកាត់ផ្តាច់ខ្លួនពីរបៀបរស់នៅរបស់លោកីយ៍ និង លែងស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោកីយ៍ទៀតហើយ។
ច) អ្នកជឿមានបេសកកម្ម សង្គ្រោះពិភពលោក ឬ ផ្សព្វផ្សាយដំណឹងល្អទៅកាន់ពិភពលោក។
ឆ) ឥរិយាបថមួយថា ក្រុមជំនុំត្រូវធ្វើអ្វីៗគ្រប់យ៉ាងដែលអាចធ្វើបាន ដើម្បីចែកចាយដំណឹងល្អ ទៅកាន់លោកីយ៍ទាំងមូល។